ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

# នីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍៖ អន្តរកាល និងការស្ថិតនៅក្នុងសេវាថែទាំ និងព្យាបាលក្នុងប្រទេសកម្ពុជា

ខែ សីហា ឆ្នាំ ២០២១

មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ

# មាតិកា


សេចក្តីថ្លែងអំណរគុណ ........ iv

អក្សរកាត់ ........ v

1. សាវតារ និងសនិទានភាព ........ 1

2. គោលបំណង ........ 2

3. និយមន័យនៃពាក្យគន្លឹះ ........ 2

4. ដំណើរការអន្តរកាល ........ 4

4.1. ដំណើរការមុនពេលអន្តរកាល ........ 4

*4.1.1. ការវាយតម្លៃបឋម* ........ 4

*4.1.2. ការផ្តល់ទិដ្ឋភាពរួមនៃផែនការនិងដំណើរការអន្តរកាល* ........ 6

4.2. ដំណាក់កាលអន្តរកាល ........ 8

*4.2.1. ជំហានសម្រាប់ការផ្ទេរចេញទៅកាន់សេវា ART មនុស្សពេញវ័យ* ........ 8

*4.2.2. ជំហានសម្រាប់ថែរក្សាយុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ ក្នុងសេវា ART កុមារ* ........ 9

4.3. ក្រោយពេលអន្តរកាល ........ 12

*4.3.1. ជំហានសម្រាប់ផ្ទេរចេញទៅសេវា ART សម្រាប់មនុស្សពេញវ័យ* ........ 12

*4.3.2. ជំហានសម្រាប់ការថែរក្សានៅសេវា PAC កុមារ* ........ 13

5. ការគាំទ្រផ្នែកផ្តល់ប្រឹក្សា ........ 15

5.1. ជំហានដើម្បីផ្តល់ប្រឹក្សា ........ 15

5.2. កម្រិតចំណេះដឹងសម្រាប់យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ ផ្អែកតាមអាយុ ........ 16

6. តួនាទីនិងទំនួលខុសត្រូវរបស់យុវវ័យដែលរស់នៅជាមួយ មេរោគអេដស៍ អាណាព្យាបាល និងអ្នកផ្តល់សេវាសុខភាព ........ 18

6.1. ការត្រៀមអន្តរកាល ........ 19

6.2. ក្នុងអំឡុងពេលអន្តរកាល ........ 20

*6.2.1. ការរៀបចំផ្ទេរចេញ* ........ 20

*6.2.2. ការថែរក្សា* ........ 24

6.3. ក្រោយអន្តរកាល ........ 26

*6.3.1. ការផ្ទេរចេញ*........26
*6.3.2. ការថែរក្សា*........27
7. **ការត្រួតពិនិត្យតាមដាន និងការរាយការណ៍**........28
7.1. **សូចនាករត្រួតពិនិត្យតាមដាន និងការរាយការណ៍**........28
7.2. **ដំណើរការគ្រប់គ្រងការត្រួតពិនិត្យតាមដាន និងការគ្រប់គ្រងការបោះបង់សេវា**........28
**ឧបសម្ព័ន្ធ**........30
ឧបករណ៍ត្រៀមអន្តរកាល........30
**ឧបសម្ព័ន្ធទី 1:** បញ្ជីផ្ទៀងផ្ទាត់សម្រាប់ការវាយតម្លៃបឋមសម្រាប់ត្រៀមអន្តរកាល (សម្រាប់អ្នកផ្តល់សេវាសុខភាព)........30
**ឧបសម្ព័ន្ធទី ២៖** ការវាយតម្លៃសុខុមាលភាព និងចំណេះដឹងមូលដ្ឋានរបស់យុវវ័យ........32
អន្តរកាលសម្រាប់ ការផ្ទេរចេញ សម្រាប់យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ អាយុ ១៥ ឆ្នាំ ឡើងទៅ....41
**ឧបសម្ព័ន្ធទី ៣៖** ការវាយតម្លៃការត្រៀមខ្លួនរបស់អ្នកជំងឺមុនពេលយុទ្ធសាស្ត្រផ្ទេរចេញថែរក្សាទុក/,ផែនការអន្តរកាលបុគ្គល និងទម្រង់ព័ត៌មាន........41
ការសន្និដ្ឋានអំពីការវាយតម្លៃការត្រៀមខ្លួន និងទម្រង់ព័ត៌មាន........44
ឧបករណ៍ក្រោយអន្តរកាល........47
**ឧបសម្ព័ន្ធទី ៤៖** ការវាយតម្លៃសម្រាប់ ក្រោយពេលផ្ទេរចេញ (អ្នកផ្តល់ប្រឹក្សា/អង្គការ /អ្នកផ្តល់សេវា)........47
**ឧបសម្ព័ន្ធទី ៥៖** ការវាយតម្លៃដោយប្រើប្រាស់ រង្វាស់ទុក្ខព្រួយរបស់ Kessler K(10)........50
**សេចក្តីបន្ថែម**........51
សេចក្តីបន្ថែម ទី១: រូបមន្តជម្រើសព្យាបាលសម្រាប់យុវវ័យ........51
សេចក្តីបន្ថែម ទី២: កម្រិតប្រើ ARV........52
សេចក្តីបន្ថែមទី ៣ ៖ សូចនាករត្រួតពិនិត្យតាមដានអន្តរកាលរបស់យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍.53
**ឯកសារយោង**........55

## *បញ្ជីរូបភាព*

**រូបភាពទី 1:** តារាងលំហូរនៃយុទ្ធសាស្ត្រផ្ទេរចេញ.....8
**រូបភាពទី 2:** តារាងលំហូរនៃយុទ្ធសាស្ត្រថែរក្សា.....11
**រូបភាពទី 3:** សង្ខេបដំណើរការអន្តរកាលរបស់យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍.....14

## *បញ្ជីតារាង*

**តារាងទី 1:** កម្រិតចំណេះដឹងដែលស្នើឡើងសម្រាប់យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ ផ្អែកតាមអាយុ.....17
**តារាង 2:** ម៉ាទ្រីសតួនាទី និងទំនួលខុសត្រូវសម្រាប់ត្រៀមអន្តរកាលនៅទីតាំង PAC.....19
**តារាងទី 3:** ម៉ាទ្រីសតួនាទីនិងទំនួលខុសត្រូវសម្រាប់ការរៀបចំផ្ទេរចេញនៅទីតាំង PAC.....20
**តារាងទី 4:** ម៉ាទ្រីសតួនាទីនិងទំនួលខុសត្រូវសម្រាប់ការថែរក្សានៅទីតាំង PAC.....24
**តារាងទី 5:** ម៉ាទ្រីសតួនាទីនិងទំនួលខុសត្រូវរបស់អ្នកផ្តល់សេវាសុខភាព យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ និងអាណាព្យាបាលនៅឯទីតាំង ART សម្រាប់មនុស្សពេញវ័យ.....26
**តារាងទី 6:** ម៉ាទ្រីសតួនាទីនិងទំនួលខុសត្រូវរបស់អ្នកផ្តល់សេវាសុខភាព យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ និងអណាព្យាបាលនៅទីតាំង PAC.....27

# សេចក្តីថ្លែងអំណរគុណ


មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ (NCHADS) សូមវាយតម្លៃខ្ពស់ និងថ្លែងអំណរគុណដល់អង្គភាពពាក់ព័ន្ធទាំងអស់របស់ខ្លួន ដែលរួមមាន ផ្នែកថែទាំជំងឺអេដស៍ (ACU), ការិយាល័យបច្ចេកទេស, ផ្នែកគ្រប់គ្រងទិន្នន័យ (DMU), កម្មវិធីអេដស៍និងកាមរោគខេត្ត និងមន្ទីរសុខាភិបាលខេត្ត មន្ទីរពេទ្យកុមារជាតិ (NPH), គ្លីនិកសុខភាពសង្គម (SHC), មន្ទីរពេទ្យខេត្តក្នុងខេត្តកំពង់ស្ពឺ និងសៀមរាប មន្ទីរពេទ្យកុមារអង្គរ (AHC) ។

សូមថ្លែងអំណរគុណជាពិសេសដល់បុគ្គលិក NCHADS (វេជ្ជ. អ៊ុក វិជ្ជា, វេជ្ជ. សំរិត សុវណ្ណរិទ្ធ, វេជ្ជ. ង៉ូវ បូរ៉ា, និង វេជ្ជ. គី សុវឌ្ឍនា, CHAI (លោកស្រី ហ៊ុល ស៊ីវណ្ណថា, វេជ្ជ. អេមី អូកាម៉ូតុ (Emi Okamoto), លោកស្រី ម៉ុក សូម៉ា-នី, លោកស្រី ឈឹម ចាន់លក្ខិណា), US-CDC (វេជ្ជ. ចាន់ សូដារា), WHO (វេជ្ជ. ដេង សិរង្គា), UNAIDS (វេជ្ជ. Win Htin Khin Cho), AHF (វេជ្ជ. ម៉ែន បញ្ញារ័ត្ន), MAGNA (លោកស្រី សាយ លក្ខិណា) និងសមាជិកក្រុមការងារបច្ចេកទេសផ្សេងទៀត ដែលបានរួមចំណែកយ៉ាងសកម្មចំពោះការរៀបចំបង្កើត នីតិវិធីប្រតិបត្តិស្តង់ដារ ស្តីពី **"អន្តរកាល ឬការថែរក្សាយុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ (ALHIV) នៅក្នុងប្រទេស"** ដោយជោគជ័យ ។

យើងសូមសំដែងនូវអំណរគុណ និងវាយតម្លៃខ្ពស់ ចំពោះការខិតខំប្រឹង និងប្តេជ្ញាចិត្តរបស់ភាគីពាក់ព័ន្ធទាំងអស់នៅក្នុងការរៀបចំឯកសារដ៏សំខាន់នេះឡើង ។


ថ្ងៃ សុក្រ ៥រោច ខែ ស្រាពណ៍ ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស ២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែសីហា ឆ្នាំ ២០២១

ប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ

វេជ្ជ.លី-ពេញ ស៊ុន

# អក្សរកាត់

| | | |
|---|---|---|
| AIDS | Acquired Immune Deficiency Syndrome (ចង្កោមរោគសញ្ញាចុះខ្សោយប្រព័ន្ធភាពស៊ាំដោយសារមេរោគឆ្លងពីខាងក្រៅ) |
| AHC | Angkor Hospital for Children (មន្ទីរពេទ្យកុមារអង្គរ) |
| ARV | Antiretroviral (drug) (ឱសថប្រឆាំងមេរោគអេដស៍) |
| ART | Anti-Retroviral Treatment (ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍) |
| ALHIV | Adolescents living with HIV (យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍) |
| FP | Family Planning (ផែនការគ្រួសារ) |
| HIV | Human Immunodeficiency Virus (វីរុសដែលធ្វើឱ្យចុះខ្សោយប្រព័ន្ធភាពស៊ាំរបស់មនុស្ស) |
| HCP | Health Care Provider (អ្នកផ្តល់ការថែទាំសុខភាព) |
| MMD | Multi-Month Dispensing (ការផ្តល់ថ្នាំសម្រាប់រយៈពេលច្រើនខែ) |
| NCHADS | National Center for HIV/AIDS, Dermatology and STD (មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ) |
| NGO | Non-government Organization (អង្គការមិនមែនរដ្ឋាភិបាល) |
| PAC | Paediatric AIDS Care (ការថែទាំជំងឺអេដស៍កុមារ) |
| SOP | Standard Operating Procedure (នីតិវិធីប្រតិបត្តិស្តង់ដារ) |
| SRH | Sexual Reproductive Health (សុខភាពផ្លូវភេទនិងសុខភាពបន្តពូជ) |
| STD | Sexual Transmitted Diseases (ជំងឺឆ្លងតាមការរួមភេទ/កាមរោគ) |
| TB | Tuberculosis (ជំងឺរបេង) |
| UNAIDS | The Joint United Nations Programme on HIV/AIDS (កម្មវិធីអង្គការសហប្រជាជាតិរួមគ្នាស្តីពីមេរោគអេដស៍/ជំងឺអេដស៍) |
| U=U | Undetectable = Untransmittable (ចំនួនមេរោគ "មិនអាចរាប់បាន = មិនអាចចម្លងបាន) |
| VH | Viral Hepatitis (ជំងឺរលាកថ្លើមដែលបង្កដោយវីរុស) |
| WHO | World Health Organization (អង្គការសុខភាពពិភពលោក) |

# 1. សាវតារ និងសនិទានភាព

អត្រាប្រេវ៉ាឡង់មេរោគអេដស៍នៅកម្ពុជាត្រូវបានប៉ាន់ស្មានថា ទាបជាង ០.៥% សម្រាប់មនុស្សពេញវ័យអាយុ ១៥-៤៩ ឆ្នាំ និង ០.១%[1] ក្នុងចំណោមយុវវ័យ ។ អេដស៍គឺជាមូលហេតុស្លាប់នាំមុខគេទី ២ ក្នុងចំណោមមូលហេតុកំពូលទាំង ១០ នៃការស្លាប់ និង ពិការភាព (អាយុដែលបាត់បង់) ក្នុងចំណោមយុវវ័យ[2] ។ ការផ្លាស់ប្តូរទៅជាយុវវ័យ និងវ័យជំទង់ គឺជាដំណាក់កាលដ៏សំខាន់មួយសម្រាប់ការអភិវឌ្ឍមនុស្ស ដែលជាកិច្ចការរបស់មនុស្សគ្រប់រូបដែលត្រូវផ្តល់ការគាំទ្រដល់ពួកគេ ជាពិសេស យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ ។ មានបញ្ហាប្រឈមជាច្រើនដែលត្រូវបានគេចងក្រងទុកជាឯកសារ និងមានពិធីសារនៅតាមទីកន្លែងផ្សេងៗ ដែលជួយអ្នកអនុវត្តន៍កម្មវិធី អ្នកតាក់តែងគោលនយោបាយសុខភាព និងគ្រួសារ កាត់បន្ថយផលប៉ះពាល់អវិជ្ជមានលើលទ្ធផលសុខភាពរបស់ពួកគេ ។ មានរបាយការណ៍មួយចំនួន ដែលបានបង្ហាញពីការកើនឡើងនៃអត្រាស្លាប់, ការបរាជ័យខាងវីរុសសាស្ត្រ[3,4], ការមិនប្រកាន់ខ្ជាប់តាមការព្យាបាល,[1,2,5] ការមិនផ្តល់តម្លៃដល់ខ្លួនឯង ការនៅឯកោម្នាក់ឯង, ការប្រើគ្រឿងញៀន, ការរំលោភបំពានផ្លូវភេទ និងការធ្វើអត្តឃាតខ្លួនឯង អំឡុងពេលអន្តរកាល ។ លើសពីនេះទៀត ក៏មានកត្តារាំងជាច្រើន ដែលយុវវ័យផ្ទុកមេរោគអេដស៍មួយចំនួន បានចាកចេញពីគ្លីនិកកុមារដោយមិនបានរៀបចំខ្លួន គ្មានផែនការច្បាស់លាស់ និងដែលជាហេតុធ្វើឱ្យការផ្ទេរទៅកាន់គ្លីនិកមនុស្សពេញវ័យមិនបានជោគជ័យ ។

អង្គការសុខភាពពិភពលោក (WHO) បានស្នើឡើងថា អន្តរកាលនៃយុវវ័យដែលរស់នៅជាមួយមេរោគអេដស៍គួរតែសង្កត់ធ្ងន់លើការត្រៀមខ្លួន ដែលកំណត់តាមរយៈ សមត្ថភាពរបស់យុវវ័យក្នុងការបង្ហាញពីការយល់ដឹងអំពីការថែទាំសុខភាពជាមូលដ្ឋាន, ការត្រៀមខ្លួនបង្ហាញស្ថានភាពមេរោគអេដស៍, ការយល់ដឹងអំពីជំងឺរបស់ពួកគេ និងការអភិវឌ្ឍជំនាញគ្រប់គ្រងសុខភាពផ្ទាល់ខ្លួនរបស់ពួកគេ[6] ។ ដើម្បីសម្រេចបានគោលដៅដ៏ល្អបំផុតនៃអន្តរកាលរបស់យុវវ័យដែលផ្ទុកមេរោគអេដស៍ គេត្រូវតែធានាឱ្យបានសមត្ថភាពក្នុងការផ្តល់ការថែទាំសុខភាពជាបន្តដោយគ្មានការអាក់ខាន, មានការសម្របសម្រួល, សមស្របចំពោះការអភិវឌ្ឍលូតលាស់, សមស្របចំពោះផ្នែកចិត្តសង្គម និងគ្រប់ជ្រុងជ្រោយ ។

ដើម្បីធានាការថែទាំសុខភាព ដោយគ្មានការអាក់ខាន និងសុខុមាលភាពរបស់យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ដោយមានភាពជាក់ស្តែង និងមានប្រសិទ្ធភាព មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍, សើ-ស្បែក និងកាមរោគ ដោយពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធសំខាន់ៗនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បាន

---

1 UNAIDS. HIV and AIDS data hub for Asia Pacific: Data Section: Factsheets: Country Factsheets: Cambodia. 2018. Accessed on 1st Sep 2019 at http://aphub.unaids.org/.

2 Bekker LG, Hosek S. HIV and adolescents: focus on young key populations. Journal of the International AIDS Society. 2015;18 (2Suppl 1).

3 Lowenthal ED, Bakeera-Kitaka S, Marukutira T, Chapman J, Goldrath K, Ferrand RA. Perinatally acquired HIV infection in adolescents from sub-Saharan Africa: a review of emerging challenges. Lancet Infect Dis. 2014;14(7):627-639.

4 Health for the World's Adolescents: A Second Chance in the Second Decade. Geneva, Switzerland: World Health Organization; 2014.

5 Haynes RB, Sackett DL, Richardson WS, Rosenberg W, Langley GR. Evidence-based medicine: How to practice & teach EBM. Canadian Medical Association. Journal. 1997 Sep 15;157(6):788.

6 World Health Organization (WHO). HIV and adolescents: guidance for HIV testing and counselling and care for adolescents living with HIV: recommendations for a public health approach and considerations for policy-makers and managers. Geneva, Switzerland: WHO; 2013.

ណែនាំឱ្យគ្លីនិក ART កុមារ និងមនុស្សពេញវ័យ ពិចារណា និងអនុវត្តដំណាក់កាលទាំងអស់នៃដំណើរការអន្តរកាល ៖ មុនពេល, ក្នុងកំឡុងពេល និងក្រោយពេលអន្តរកាល ។ អន្តរាគមន៍ប្រកបដោយប្រសិទ្ធភាពសម្រាប់អន្តរកាលនៃការថែទាំយុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ ការណែនាំសម្រាប់ការអនុវត្តនិងការបណ្តុះបណ្តាល ចាំបាច់ត្រូវតែរៀបចំឱ្យមាននៅគ្រប់កម្រិតថ្នាក់ ។

ការយល់ចំណេះដឹងនៅមានកម្រិតអំពីយុទ្ធសាស្ត្រអន្តរកាលរបស់យុវវ័យ ដែលត្រូវបានដាក់ឱ្យអនុវត្ត និងធ្វើការវាយតម្លៃនៅក្នុងប្រទេសក្នុងពេលកន្លងមក ដែលនេះគឺជាគម្លាតនៃចំណេះដឹង និងគំរូដែលអាចផ្ទេរបាន ។ ដូច្នេះ ដំណើរការអន្តរកាលដែលបានស្នើឡើងសម្រាប់អន្តរកាលយុវវ័យនៅក្នុងប្រទេសកម្ពុជា ត្រូវបានណែនាំ និងដាក់ចេញនៅក្នុងផ្នែកទី ៤ ខាងក្រោម ។

## 2. គោលបំណង

គោលបំណងនៃនីតិវិធីប្រតិបត្តិស្តង់ដារនេះគឺដើម្បីផ្តល់ការណែនាំ ជាជំហានៗសម្រាប់អ្នកផ្តល់សេវាថែទាំសុខភាពនៅ ART, អាណាព្យាបាល, បណ្តាញគាំទ្រ និងយុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ ដើម្បីធ្វើអន្តរកាលដោយជោគជ័យនៅក្នុងគ្លីនិក ART ឬដើម្បីផ្ទេរចេញដោយជោគជ័យពីសេវាថែទាំព្យាបាលជំងឺអេដស៍កុមារ ទៅកាន់សេវា ART សម្រាប់មនុស្សពេញវ័យ ។

## 3. និយមន័យនៃពាក្យគន្លឹះ

- **យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍** (Adolescent living with HIV): អង្គការ UNAIDS កំណត់និយមន័យយុវវ័យថាជា បុគ្គលដែលមានអាយុចាប់ពី ១០ ទៅ ១៩ ឆ្នាំ ដែលភាពយុវវ័យចាប់ផ្តើមជាមួយនឹងភាពពេញវ័យ តាមធម្មតាផ្នែកសរីរសាស្ត្រ ហើយចប់ទៅនៅពេលដែលអត្តសញ្ញាណ និងឥរិយាបថរបស់មនុស្សពេញវ័យ ត្រូវបានគេទទួលយក ។[7,8]
- **អន្តរកាលយុវវ័យ** (Adolescent transition) គឺជា "ចលនាដែលមានគោលដៅ និងផែនការច្បាស់លាស់របស់យុវវ័យ និងមនុស្សពេញវ័យវ័យក្មេង ដែលមានលក្ខខណ្ឌសុខភាពរាងកាយ និងវេជ្ជសាស្ត្ររ៉ាំរ៉ៃ ពីប្រព័ន្ធថែទាំសុខភាពដែលផ្តោតលើកុមារ ទៅជាប្រព័ន្ធថែទាំសុខភាពដែលផ្តោតលើមនុស្សពេញវ័យ"[9] ។ វាគឺជាដំណាក់កាលដ៏សំខាន់មួយសម្រាប់ការអភិវឌ្ឍមនុស្ស ហើយវាមានសារៈសំខាន់ ដើម្បីផ្តល់ការគាំទ្រប្រកបដោយប្រសិទ្ធភាពដើម្បីភ្ជាប់យុវវ័យទៅនឹងដំណាក់កាលបន្ទាប់ ដែលគេហៅថា មនុស្សពេញវ័យ ។

---

[7] AMC. Age limits and adolescents. Paediatric Child Health, 2003; 8(9): 577, https://www.ncbi.nlm.nih.gov/pmc/articles/PMC2794325/.

[8] World Health Organization (WHO). HIV and adolescents: guidance for HIV testing and counselling and care for adolescents living with HIV: recommendations for a public health approach and considerations for policymakers and managers. Geneva, Switzerland: WHO; 2013.

[9] Blum RW, Garell D, Hodgman CH, Jorissen TW, Okinow NA, Orr DP, Slap GB. Transition from child-centered to adult health-care systems for adolescents with chronic conditions: a position paper of the Society for Adolescent Medicine. Journal of Adolescent Health. 1993 Nov 1;14(7):570-6.

វាកាន់តែសំខាន់ថែមទៀត ក្នុងការផ្ទេរដោយរលូននូវយុវវ័យដែលមានលក្ខខណ្ឌសុខភាពខ្សោយ ឬ រ៉ាំរ៉ៃរយៈពេលវែង ។

- ពាក្យថា "**អន្តរកាល**" ("Transition") សំដៅលើដំណើរការ ដែលរួមមានការវាយតម្លៃ, ការថែរក្សាអ្នកជំងឺឲ្យនៅក្នុងសេវាទៅថ្ងៃមុខ និងការផ្ទេរចេញជាក់ស្តែង ទៅសេវាមនុស្សពេញវ័យ ។ អន្តរកាល គឺមិនគិតថាតើយុវវ័យត្រូវបានផ្ទេរចេញជាក់ស្តែង ទៅសេវាមនុស្សពេញវ័យ ឬនៅតែស្ថិតនៅក្នុងសេវាART ដដែល ឬកំពុងរៀបចំផ្ទេរចេញក្តី ។ អន្តរាគមន៍ និងដំណើរការដែលបានបញ្ជាក់ក្នុងផ្នែកទី ៤ ណែនាំបន្ថែមដល់អ្នកផ្តល់សេវាថែទាំសុខភាព, បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល ឬអ្នកស្ម័គ្រចិត្ត, អាណាព្យាបាល និងអ្នកជំងឺនៅក្នុងគ្រប់ដំណើរការនេះ ។
- **ការផ្ទេរចេញ** (Transfer-out) សំដៅលើរយៈពេលមួយ ដែលយុវវ័យចាប់ផ្តើមជួបប្រទះបរិយាកាសថ្មីនៃការថែទាំ ដែលក្នុងនោះ គាត់ត្រូវបានបណ្តុះបណ្តាលជំនាញ និងចំណេះដឹងមួយចំនួននៅកន្លែងថែទាំបច្ចុប្បន្ន មុននឹងប្តូរទៅកន្លែង ART មួយទៀត ។ *(សូមមើលផ្នែកទី 4.2.1).* **ការផ្ទេរចេញនេះ** អាចជាលក្ខណៈបុគ្គល ឬជាក្រុម ហើយអាចត្រូវបានអមដំណើរ/សម្របសម្រួលដោយបុគ្គលិកសុខាភិបាល/អ្នកស្ម័គ្រចិត្ត (ពោលគឺ អង្គការក្រៅរដ្ឋាភិបាល) អាស្រ័យលើធនធានដែលមាននៅនឹងកន្លែង ។
- **ការថែរក្សាឲ្យនៅក្នុងសេវា** (Retention) សំដៅលើរយៈពេល ដែលយុវវ័យម្នាក់នៅតែស្ថិតក្នុងដំណាក់-កាលរៀបចំខ្លួននៅក្នុងទីកន្លែង ART ដដែល ដោយទទួលស្គាល់ការពិតដែលថា គាត់មិនទាន់ត្រៀមរួចរាល់ដើម្បីទទួលការថែទាំនិងការព្យាបាល នៅសេវាមួយទៀតទេ ។ វា គឺជាដំណាក់កាលមួយនៅក្នុងដំណើរការអន្តរកាល ។ ស្ថានភាពនៃការថែរក្សា គួរតែត្រូវបានបញ្ជាក់ដោយការវាយតម្លៃជាក់លាក់មួយដែលធ្វើឡើងដោយអ្នកផ្តល់សេវាសុខភាព និងចុងក្រោយ បញ្ជាក់ដោយអាណាព្យាបាលជាមួយយុវវ័យខ្លួនឯង។ *(សូមមើលផ្នែកទី 4.2.2.).*
- **គម្រោងពេលអន្តរកាល** (Transition timeline) សំដៅលើការចាប់ផ្តើមពីមុនពេលអន្តរកាលរហូតដល់ការបញ្ចប់អន្តរកាល ។ នេះ គឺជាគម្រោងពេល ដែលអាចមាន ឬ ដែលអាចត្រូវការដើម្បីវាយតម្លៃ និងវាយតម្លៃឡើងវិញ ក្នុងរយៈពេលមុនអន្តរកាល និងអន្តរកាល ។ រយៈពេលនេះក៏ផ្តល់ជាគំនិត និងការត្រៀមរួចរាល់ផ្នែកផ្លូវចិត្តសម្រាប់អាណាព្យាបាល ក៏ដូចជាអ្នកផ្តល់ការថែទាំសុខភាព អំពីពេលវេលាដែលអាចត្រូវការសម្រាប់អន្តរកាលដោយជោគជ័យ ។ នៅក្នុងបរិបទនេះ អន្តរកាលចាប់ផ្តើមនៅពេលយុវវ័យមានអាយុពី ១០ ទៅ ១៤ ឆ្នាំ ប៉ុន្តែ អន្តរកាលនេះអាចបត់បែនបានដោយផ្អែកលើការត្រៀមខ្លួនរួចរាល់របស់យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ម្នាក់ៗ ។

# 4. ដំណើរការអន្តរកាល

ក្របខ័ណ្ឌខាងក្រោមនេះ បង្ហាញពីលំហូរនៃដំណើរការនៃអន្តរកាល ដោយចាប់ផ្តើមពីពេលមុនអន្តរកាល, ក្នុងពេលអន្តរកាល និងក្រោយពេលអន្តរកាល ។ មានក្របខ័ណ្ឌបី ដែលរួមមាន យុទ្ធសាស្ត្រផ្ទេរចេញ (រូបភាពទី ១),

យុទ្ធសាស្ត្រថៃរក្សាទុកនៅសេវាដដែល (រូបភាពទី ២) និងសេចក្តីសង្ខេបអន្តរកាលយុវវ័យ ដែលរស់នៅជាមួយមេរោគអេដស៍ (រូបភាពទី ៣) ។ រូបភាពទាំងពីរ(រូបភាពទី ១ និងរូបភាពទី ២)គឺជាក្របខ័ណ្ឌលម្អិតនៃSOPនេះ ។

## 4.1. ដំណើរការមុនពេលអន្តរកាល

### *4.1.1. ការវាយតម្លៃបឋម*

ដំណើរការមុនអន្តរកាល គួរតែត្រូវបានធ្វើឡើងដើម្បីវាយតម្លៃភាពសមស្រប ការត្រៀមរួចរាល់ និងការទទួលបានរបស់អ្នកជំងឺ ដូចដែលបានពិពណ៌នា នៅក្នុងលក្ខណវិនិច្ឆ័យខាងក្រោម ។ ដោយដឹងអំពីភាពសមស្របរបស់ពួកគេ អ្នកផ្តល់សេវាសុខភាពពិគ្រោះយោបល់ជាមួយយុវវ័យដែលរស់នៅជាមួយមេរោគ-អេដស៍ (ALHIV) និងអាណាព្យាបាលរបស់ពួកគេ ដើម្បីធានាថា ពួកគេយល់ និងធ្វើតាមដំណើរការមុនពេលអន្តរកាល ។ គួរតែមានការវាយតម្លៃជាមូលដ្ឋានខ្លះដើម្បីធានាថា យុវវ័យត្រៀមខ្លួនរួចរាល់ដើម្បីឈានទៅរកដំណាក់កាលត្រៀមចូលមនុស្សពេញវ័យ ៖

1) **ពិនិត្យមើលលក្ខណវិនិច្ឆ័យនៃភាពសមស្រប៖** ភាពសមស្របនៃអាយុ, លទ្ធផលបន្ទុកមេរោគពីរដងចុងក្រោយ (ដែលមានបន្ទុកមេរោគមិនអាចរកឃើញសម្រាប់ជម្រើសផ្ទេរចេញ) និងការត្រៀមបង្ហាញពីស្ថានភាពមេរោគអេដស៍ ។
2) **ធ្វើការវាយតម្លៃការអប់រំសុខភាពបឋម៖** សុខុមាលភាពកុមារ (រួមបញ្ចូលទាំងរូបមន្ត ARV) និងចំណេះដឹងអំពីសុខភាពនៅពេលវាយតម្លៃមូលដ្ឋាន និងធនធានដែលត្រូវការ ។

ចំណុចលម្អិតបន្ថែមទៀតនៃដំណើរការទាំងនេះ មានដូចខាងក្រោម ៖

#### *1) ពិនិត្យឡើងវិញលើលក្ខណវិនិច្ឆ័យ នៃភាពសមស្រប*

ប្រើបញ្ជីត្រួតពិនិត្យសម្រាប់ការវាយតម្លៃបឋម ដើម្បីជ្រើសរើសអ្នកជំងឺដែលសមស្របនៅក្នុងទីតាំង ART នីមួយៗ ដោយពិនិត្យមើលលក្ខណវិនិច្ឆ័យនៃភាពសមស្របរបស់យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍, ការវាយតម្លៃសុខុមាលភាពរបស់យុវវ័យ (**ឧបសម្ព័ន្ធទី ២ ផ្នែកទី I**), និងធ្វើការវាយតម្លៃទីតាំងដូចមានបង្ហាញនៅក្នុង *ឧបសម្ព័ន្ធទី ១ - បញ្ជីត្រួតពិនិត្យសម្រាប់ការវាយតម្លៃបឋមមុនពេលអន្តរកាល ។*

- **អាយុសមស្រប (Eligible Age):** បទពិសោធន៍ពីអង្គការក្រៅរដ្ឋាភិបាលដែលធ្វើការលើបញ្ហានេះ (MAGNA និង AHC) បង្ហាញថា អន្តរកាល គួរធ្វើឡើងយោងតាមក្រុមអាយុ៖ ១) យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ (ALHIV) អាយុពី ១០ – ១៤ ឆ្នាំ និង ២) អាយុ > ១៥ ឆ្នាំ ។

  *អាយុដែលបានណែនាំដើម្បីចាប់ផ្តើមត្រៀមអន្តរកាល គឺចាប់ពីអាយុ ១០ ឆ្នាំ ហើយការផ្ទេរចេញគួរតែចាប់ផ្តើមយ៉ាងហោចណាស់នៅពេលយុវវ័យមានអាយុយ៉ាងតិច ១៥ ឆ្នាំ ។ គាត់គួរតែត្រូវបានវាយតម្លៃរៀងរាល់ ៣-៦ ខែម្តង ។*

- **លទ្ធផលតេស្តរាប់បន្ទុកមេរោគ ពីរដងចុងក្រោយ៖** លទ្ធផលនៃបន្ទុកមេរោគ ពីរដងចុងក្រោយត្រូវតែធ្វើការវាយតម្លៃដើម្បីធានាការបង្ក្រាបមេរោគ ក្នុងកម្រិតដែលចំនួនមេរោគមិនអាចរាប់បាន

និងការគ្រប់គ្រងមេរោគក្នុងឈាមបានល្អ។ មុននឹងបន្តធ្វើការផ្ទេរចេញ យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ គួរតែមានលទ្ធផលបន្ទុកមេរោគដែលមិនអាចរាប់បាន ពីរដងចុងក្រោយក្នុងរយៈពេល ៦ ខែចុងក្រោយ *យោងតាមបទពិសោធន៍របស់ អង្គការម៉ាកណា (MAGNA) ក្នុងការផ្ទេរក្មេងជំទង់ និង បទពិសោធន៍ជាក់ស្តែង របស់មន្ទីរពេទ្យកុមារអង្គរ ក្នុងការផ្ទេរអ្នកជំងឺដែលមានស្ថិរភាព (stable patients) ។*

- **របមន្ត/ប្រភេទថ្នាំប្រឆាំងមេរោគអេដស៍** (ARV regimens): ជាការសំខាន់ដែលគ្រូពេទ្យ អ្នកផ្តល់ប្រឹក្សា យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ និងអាណាព្យាបាល ត្រូវទទួលបានព័ត៌មានបច្ចុប្បន្នភាពអំពីរូបមន្ត ARV ឬការផ្លាស់ប្តូររូបមន្តនាពេលអនាគត ដោយផ្អែកលើការឡើងទម្ងន់របស់អ្នកជំងឺ និងការផ្លាស់ប្តូរក្នុងស្ថានភាពសុខភាពរបស់យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ ។ ប្រសិនបើអ្នកជំងឺទើបតែត្រូវបានប្តូរទៅរូបមន្តថ្មី ហើយនៅតែមិនមានស្ថិរភាព ការផ្ទេរចេញនៅពេលនេះមិនត្រូវបានណែនាំនោះទេ ហើយពួកគេគួរតែត្រូវបានរក្សាទុកនៅក្នុងសេវា PAC ដដែល ( *សូមមើលសេចក្តីបន្ថែមទី១ និងទី ២ សម្រាប់ការផ្តល់ប្រឹក្សាអំពីរូបមន្តឬប្រភេទនិងកម្រិតប្រើ ARV)*

- **ការបង្ហាញពីស្ថានភាពមេរោគអេដស៍៖** យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ គួរតែដឹងអំពីស្ថានភាពមេរោគអេដស៍របស់ពួកគេ ។ ប្រសិនបើអ្នកជំងឺមិនទាន់បានដឹងអំពីស្ថានភាពមេរោគអេដស៍របស់ខ្លួនទេ អ្នកផ្តល់សេវាថែទាំសុខភាពគួរតែពិភាក្សា និងសហការជាមួយអាណាព្យាបាល ដើម្បីបង្ហាញពីស្ថានភាពមេរោគអេដស៍ដល់យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍មុននឹងបន្តធ្វើការផ្ទេរចេញ ។ សម្រាប់ការរក្សាទុក អ្នកផ្តល់សេវានិងអាណាព្យាបាលគួរតែធ្វើការរួមគ្នា ដើម្បីបង្ហាញស្ថានភាពមេរោគអេដស៍ជាជំហានៗ ។

  *ដើម្បីទទួលបានលទ្ធផលកាន់តែប្រសើរ ការបង្ហាញពីស្ថានភាពមេរោគអេដស៍ ឬជំងឺឱ្យកុមារដែលមានផ្ទុកមេរោគអេដស៍ឱ្យបានដឹងពីដំបូង គួរត្រូវបានធ្វើឡើងឱ្យបានឆាប់តាមដែលអាចធ្វើទៅបានដោយអ្នកផ្តល់សេវាសុខភាព និងអាណាព្យាបាល ។ កុមារដែលពន្យារពេលការបង្ហាញពីស្ថានភាពមេរោគអេដស៍របស់ពួកគេ អាចមានមូលហេតុពីមុនមកទាក់ទងនឹង បញ្ហាផ្លូវចិត្ត និងចិត្តសង្គម ។ បន្ទាប់មក អ្នកផ្តល់សេវាសុខភាពអាចនឹងមានការរារែក ឬសម្រេចចិត្តពន្យារពេលការបង្ហាញព័ត៌មាននេះ ដែលជាផលវិបាក ធ្វើឱ្យកុមារមានលទ្ធផលក្នុងការសិក្សានៅសាលាមិនបានល្អ ហើយថែមទាំងមាន/បង្កជាបញ្ហាសុខភាពផ្លូវចិត្តខ្លះទៀតផង ។ យោងតាមការសិក្សារបស់ប្រទេសរ៉ូម៉ានី កុមារដែលមានអាយុពី ៥ ទៅ ១៧ ឆ្នាំ ដែលត្រូវបានគេបង្ហាញឱ្យដឹងពីស្ថានភាពមេរោគអេដស៍របស់ពួកគេ មានហានិភ័យចំពោះការស្លាប់ក្នុងរយៈពេល ៣ ឆ្នាំ តិចជាងពាក់កណ្តាលនៃកុមារដែលមិនត្រូវបានគេបង្ហាញពីស្ថានភាពអេដស៍របស់ពួកគេ។*[10]

---

[10] WHO, 2011: Guideline on HIV disclosure counselling for children up to 12 years of age (see Appendix B for Summary of Findings and GRADE Tables comparing children disclosed to with those who are not disclosed to, online at http://www.who.int/hiv/topics/vct/en/index.html)

### 2) ធ្វើការវាយតម្លៃការអប់រំសុខភាព៖

- **ការវាយតម្លៃសុខុមាលភាព៖** ប្រើឧបករណ៍វាយតម្លៃសុខុមាលភាពកុមារ ដើម្បីកំណត់ និងវិភាគបញ្ហាប្រឈមដែលរារាំងដល់ការត្រៀមខ្លួនរបស់យុវវ័យក្នុងការធ្វើអន្តរកាល រួមទាំងអាហារូបត្ថម្ភ ការអភិវឌ្ឍផ្លូវចិត្ត បញ្ហាទាក់ទងនឹងសុខភាព និងស្ថានភាពសង្គមសេដ្ឋកិច្ច (*សូមមើល ឧសម្ព័ន្ធទី ២៖ ឧបករណ៍វាយតម្លៃសុខុមាលភាពនិងចំណេះដឹងជាមូលដ្ឋានរបស់យុវវ័យ*)[11]។

  បន្ថែមពីលើនេះ អ្នកផ្តល់សេវាសុខភាពកុមារ គួរធ្វើការតាមដានលើសុខភាព ទំនុកចិត្ត ការត្រៀមខ្លួន និងធនធានរបស់កុមារ ជាពិសេស ការបង្ហាញស្ថានភាពមេរោគអេដស៍ និងធ្វើការពិនិត្យឡើងវិញយ៉ាងតិច ៦ ខែ ទៅលើលក្ខណវិនិច្ឆ័យ/សំណួរសំខាន់ៗ ។

- **ការវាយតម្លៃចំណេះដឹងផ្នែកសុខភាពនៅដើមគ្រា៖** ជាការសំខាន់ដែលអ្នកផ្តល់សេវាសុខភាពត្រូវដឹងអំពីកម្រិតចំណេះដឹងរបស់អ្នកជំងឺរបស់គាត់ ជាពិសេសចំណេះដឹងផ្នែកសុខភាពជាមូលដ្ឋាន (កម្រិតទី១) មុនពេលអន្តរកាល ។ ចំណេះដឹងកម្រិតទី ១ រួមមានអនាម័យផ្ទាល់ខ្លួន ចំណេះដឹងជាមូលដ្ឋានអំពីមេរោគអេដស៍ កាយវិភាគសាស្ត្រ និងការរៀបចំខ្លួនក្នុងការបង្ហាញស្ថានភាពមេរោគអេដស៍ ។ ការវិវឌ្ឍនៃសុខភាពគួរត្រូវបានវាយតម្លៃជាបន្តបន្ទាប់សម្រាប់ចំណេះដឹងគ្រប់កម្រិតទាំងអស់ ។

  បន្ទាប់ពីធ្វើការវាយតម្លៃចំណេះដឹងអំពីសុខភាព អ្នកផ្តល់សេវាសុខភាពពិនិត្យមើល***ធនធានដែលត្រូវការសម្រាប់ការផ្ទេរចេញ ដែលរួមបញ្ចូលទាំងសមត្ថភាពរបស់ទីកន្លែង និងអ្នកជំងឺ***ដែលកំពុងរៀបចំសម្រាប់ជំហានបន្ទាប់នៅក្នុងដំណាក់កាលអន្តរកាល ។ ការពិនិត្យមើលសមត្ថភាពរបស់ទីតាំង រួមមានការពិនិត្យឡើងវិញលើរបាយការណ៍ ឬកំណត់ត្រាអំពីអ្នកជំងឺម្នាក់ៗប្រចាំសប្តាហ៍ ឬប្រចាំខែ (អាស្រ័យលើការអនុវត្តជាប្រចាំរបស់ទីតាំងនោះ) ដើម្បីជ្រើសរើសអាយុសមស្រប របស់កុមារ និងលក្ខណវិនិច្ឆ័យផ្សេងទៀតដូចដែលបានរំលេចនៅក្នុង***ឧបសម្ព័ន្ធទី ១***។ ការពិនិត្យមើលសមត្ថភាពអ្នកជំងឺ គឺពាក់ព័ន្ធនឹងលទ្ធផលនៃការអប់រំសុខភាព ។ បន្ទាប់ពីការពិនិត្យរួចមកអ្នកផ្តល់សេវាសុខភាព រៀបចំបញ្ជីសង្ខេបនៃអ្នកជំងឺដែលមានភាពសមស្រប ហើយធ្វើការណាត់ជួបដើម្បីពិភាក្សាក្នុងអំឡុងពេលផែនការ និងដំណើរការអន្តរកាល ។

### 4.1.2. *ការផ្តល់ទិដ្ឋភាពរួមនៃផែនការនិងដំណើរការអន្តរកាល*

- បន្ទាប់ពីការវាយតម្លៃបឋម អ្នកផ្តល់សេវាសុខភាពពិភាក្សាជាមួយយុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ ដែលមានភាពសមស្រប/ដែលត្រូវបានជ្រើសរើស អំពីផែនការអន្តរកាលរបស់គាត់ ថាតើគាត់

[11] This tool is adapted from ***Annex 14: Child well-being assessment tool,*** *Chapter 40 of the Cambodian National HIV clinical management guideline for infants, children, and adolescents fifth edition 2019).*

មានបំណងស្ថិតនៅកន្លែងដដែល ឬផ្ទេរចេញ ។ ផែនការនេះអាចត្រូវបានអនុវត្តដោយឡែក ឬរួមគ្នាជាមួយអាណាព្យាបាលរបស់ពួកគេ ។

i. ប្រសិនបើយុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ និងអាណាព្យាបាលរបស់គាត់ មានបំណងផ្ទេរចេញទៅកាន់ ART សម្រាប់មនុស្សពេញវ័យ, អ្នកផ្តល់សេវាសុខភាពត្រូវអនុវត្តតាមជំហាននានា ដែលបានដាក់ចេញក្នុងចំណុច B.1 (រូបភាពទី ១) ។

ii. ប៉ុន្តែ ប្រសិនបើពួកគេចង់បន្តនៅក្នុងគ្លីនិក ART កុមារ អ្នកផ្តល់សេវាសុខភាពត្រូវអនុវត្តតាមចំណុច B.2 (រូបភាពទី ២) ។

- អ្នកផ្តល់សេវាសុខភាពទទួលការយល់ព្រមដោយផ្អែកលើព័ត៌មានដែលមាន ដើម្បីប្តូរទៅដំណាក់កាលបន្ទាប់ ។ ប្រសិនបើយុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ និងអាណាព្យាបាល ត្រូវផ្ទេរចេញ ពួកគេនឹងត្រូវបានពន្យល់ជូនអំពីលក្ខណវិនិច្ឆ័យនៃការផ្ទេរចេញទី ៤ *(ឧបសម្ព័ន្ធទី ៣ ៖ ការវាយតម្លៃការត្រៀមខ្លួនរបស់អ្នកជំងឺ ផែនការអន្តរកាលបុគ្គល និងទម្រង់ព័ត៌មាន)* ។
- នៅពេលយុវវ័យដែលរស់នៅជាមួយមេរោគអេដស៍និងអាណាព្យាបាល មិនទាន់ត្រៀមខ្លួនរួចរាល់សម្រាប់អន្តរកាលទេ ពួកគេនឹងត្រូវបានវាយតម្លៃឡើងវិញដូចមានបញ្ជាក់ក្នុងចំណុច A (រូបភាពទី ១) រៀងរាល់ ៣-១២ ខែម្តង រហូតដល់ពួកគេត្រៀមខ្លួនរួចរាល់ដើម្បីប្តូរទៅដំណាក់កាលបន្ទាប់ ។

# 4.2. ដំណាក់កាលអន្តរកាល

## *4.2.1. ជំហានសម្រាប់ការផ្ទេរចេញទៅកាន់សេវា ART មនុស្សពេញវ័យ*




*រូបភាពទី 1: តារាងលំហូរនៃយុទ្ធសាស្ត្រផ្ទេរចេញ*

ក្នុងការរៀបចំសម្រាប់យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ ដែលមានបំណងចង់ផ្ទេរចេញ សកម្មភាពសំខាន់ៗមួយចំនួនគួរត្រូវបានធ្វើឡើងនៅទីតាំង PAC ៖

1) *ការកត់ត្រា និងការត្រួតពិនិត្យតាមដាន និងវាយតម្លៃ៖* អ្នកផ្តល់សេវាសុខភាព ពិនិត្យឡើងវិញនិងធ្វើចំណាត់ថ្នាក់អ្នកជំងឺ (ចំណេះដឹង, រូបមន្តព្យាបាល, ធនធានដែលត្រូវការ ។ល។) យោងតាមអាយុ និង ផែនការអន្តរកាល របស់បុគ្គលម្នាក់ៗ ។

2) *ផ្តួចផ្តើមផែនការផ្ទេរចេញរបស់បុគ្គល ៖* អ្នកផ្តល់សេវាសុខភាព ផ្តួចផ្តើមផែនការផ្ទេរចេញជាមួយយុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ និង/ឬ អាណាព្យាបាល ហើយទទួលទម្រង់យល់ព្រម ។ ផែនការផ្ទេរចេញរបស់បុគ្គល នឹងជួយអ្នកផ្តល់សេវាសុខភាព ដើម្បីយល់ច្បាស់អំពីស្ថានភាពអ្នកជំងឺដោយសហការជាមួយអ្នកជំងឺ និងអាណាព្យាបាល ។

3) *វាយតម្លៃជាមុន លើការត្រៀមខ្លួនរួចរាល់របស់អ្នកជំងឺសម្រាប់ការផ្ទេរចេញ៖* ការវាយតម្លៃជាមុនលើអ្នកជំងឺនេះ គឺជាមូលដ្ឋានសម្រាប់អ្នកផ្តល់សេវា ដើម្បីជួយក្នុងការវាយតម្លៃអំពីការត្រៀមខ្លួនរួចរាល់សម្រាប់ការផ្ទេរចេញ ។ ឧបករណ៍ទាំងឡាយខាងក្រោមនេះ នឹងត្រូវបានប្រើប្រាស់ *(ឧបសម្ព័ន្ធទី ៣ ៖ ការវាយតម្លៃលើការត្រៀមខ្លួនរួចរាល់របស់អ្នកជំងឺ ផែនការអន្តរកាលរបស់បុគ្គល និងទម្រង់យល់ព្រម)*

4) *ការផ្តល់ប្រឹក្សា, ការគាំទ្រផ្នែកចិត្តសង្គមនិងការអប់រំ៖* អ្នកផ្តល់សេវាសុខភាពផ្តល់ប្រឹក្សាពិសេសដល់យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍តាមតម្រូវការ រួមជាមួយឬក្នុងអំឡុងវគ្គអប់រំសុខភាព (កម្រិតទី១ និង ទី២) ជួយដល់ការបង្ហាញពីស្ថានភាពមេរោគអេដស៍ និងពង្រឹងបំណិនជីវិត) *(សម្រាប់ព័ត៌មានលម្អិតអំពីការប្រឹក្សា សូមមើលជំពូកទី ៥)*

5) *សេវាមេត្រីភាព សម្រាប់យុវជន៖* អ្នកផ្តល់សេវាសុខភាពធានាបរិយាកាសប្រកបដោយមេត្រីភាពសម្រាប់យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ ជាពិសេស អ្នកដែលអាចនឹងត្រូវការការគាំទ្រពិសេស អ្នកផ្តល់សេវាសុខភាព ពិចារណាផ្តួចផ្តើមក្រុមគាំទ្រមិត្តភក្តិ ឬតភ្ជាប់ទៅនឹងសេវារបស់អង្គការក្រៅរដ្ឋាភិបាលណាមួយ ។ សេវាមេត្រីភាពយុវវ័យ គួរតែត្រូវបានផ្តល់ជូននៅគ្រប់ទីតាំង PAC និងទីតាំងគ្លីនិកមនុស្សពេញវ័យ ដែលយុវវ័យអាចទទួលបានការថែទាំ (ទាំងកុមារ និងមនុស្សពេញវ័យ) ។ សមាសភាគនៃសេវាមេត្រីភាពយុវវ័យ អាចរួមមាន៖ ការរៀបចំឱ្យមានទីកន្លែងមេត្រីភាពយុវវ័យ, ការរៀបចំឱ្យមានសេវាមេត្រីភាពយុវវ័យ និងការប្រកាន់យកអាកប្បកិរិយាមេត្រីភាពយុវវ័យ *(សូមមើលជំពូកទី ៤០ នៃគោលការណ៍ណែនាំជាតិរបស់កម្ពុជាស្តីពីការគ្រប់គ្រងព្យាបាលមេរោគអេដស៍សម្រាប់ទារក កុមារ និងយុវវ័យ បោះពុម្ពលើកទី ៥ ឆ្នាំ ២០១៩)* ។

6) *វាយតម្លៃការត្រៀមខ្លួនរួចរាល់របស់អ្នកជំងឺសម្រាប់ការផ្ទេរចេញក្រោយពេលផ្ទេរចេញ៖* ក្នុងគោលបំណងស្រដៀងគ្នានឹងគោលដៅដែលបានបញ្ជាក់នៅក្នុងចំណុចទី៣ ខាងលើ, អ្នកផ្តល់សេវាសុខភាពគួរតែបំពេញការវាយតម្លៃលើការត្រៀមខ្លួនរបស់អ្នកជំងឺក្រោយការផ្ទេរចេញ បន្ទាប់ពីបញ្ចប់

ដំណើរការរៀបចំ *(ឧបករណ៍ដូចគ្នាក្នុងការវាយតម្លៃអ្នកជំងឺមុនពេលផ្ទេរចេញ សូមមើលឧបសម្ព័ន្ធទី ៤)* ។ បន្ទាប់ពីការវាយតម្លៃរួច អ្នកផ្តល់សេវាសុខភាពនឹងយល់ថា តើអ្នកជំងឺណាខ្លះដែលអាចត្រៀមខ្លួនរួចរាល់ឬមិនរួចរាល់ ហើយធ្វើសកម្មភាពដូចខាងក្រោម ៖

i. ប្រសិនបើយុវវ័យដែលរស់នៅជាមួយមេរោគអេដស៍**ត្រៀមខ្លួនរួចរាល់ដើម្បីផ្ទេរចេញ**, អ្នកផ្តល់សេវាសុខភាពគួរប្រើឧបសម្ព័ន្ធទី ៦ ៖ បញ្ជីផ្ទៀងផ្ទាត់ការបញ្ជូន និងទម្រង់យល់ព្រមជាលាយលក្ខណ៍អក្សរសម្រាប់អ្នកជំងឺនិងអាណាព្យាបាល ដើម្បីផ្ទៀងផ្ទាត់មើលបញ្ជីដែលពាក់ព័ន្ធទាំងអស់ដែលត្រូវបំពេញ និងចុះហត្ថលេខាលើទម្រង់យល់ព្រមសម្រាប់ការព្រមព្រៀង ។ បន្ទាប់មក អ្នកផ្តល់សេវាសុខភាព អនុញ្ញាតឱ្យយុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ និងអាណាព្យាបាលរបស់គាត់ ស្នើឡើងនូវទីតាំង ART សម្រាប់មនុស្សពេញវ័យ, ពិនិត្យមើលបញ្ជីសេវាដែលបានធ្វើបច្ចុប្បន្នភាពដើម្បីស្វែងរកអ្នកផ្តល់សេវាសុខភាព ដែលនឹងទទួលខុសត្រូវចំពោះយុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ ដែលនឹងត្រូវផ្ទេរចេញក្នុងពេលឆាប់ៗ និងធ្វើការណាត់ជួបជាមួយអ្នកផ្តល់សេវាសុខភាពនៅទីតាំង ART សម្រាប់មនុស្សពេញវ័យ ។ អ្នកផ្តល់សេវាសុខភាពរៀបចំឯកសារដូចខាងក្រោមដើម្បីផ្ទេរចេញ ៖

   a) **លិខិតបញ្ជូនដោយមន្ទីរពេទ្យ ៖** នេះគឺជាទម្រង់សង្ខេបមួយដែលផ្តល់នូវទិន្នន័យអំពីអ្នកជំងឺសម្រាប់បុគ្គលិក ART ថ្មី ។ លិខិតនេះក៏មានបញ្ជាក់ប្រវត្តិព្យាបាលអ្នកជំងឺម្នាក់ៗ, លទ្ធផលតេស្តបន្ទុកមេរោគ និងតេស្តផ្សេងៗទៀត ។

   b) **ទម្រង់ប្រវត្តិអ្នកជំងឺសង្ខេប ៖** អ្នកផ្តល់សេវាសុខភាព សង្ខេប បញ្ជីអ្នកជំងឺ ដែលត្រូវផ្ទេរចេញទៅទីតាំង ART មួយទៀត ។

ii. ប្រសិនបើយុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ មិនទាន់ត្រៀមខ្លួនរួចរាល់ដើម្បីផ្ទេរចេញទេ គាត់គួរបន្តក្នុងដំណើរការរៀបចំខ្លួន និងវាយតម្លៃឡើងវិញលើការត្រៀមខ្លួនរួចរាល់របស់គាត់ក្នុងរយៈពេល **៣ ដល់ ១២ ខែ បន្ទាប់** *(សូមមើលចំណុចទី 4.2.2. យុទ្ធសាស្ត្រថែរក្សា)* ។

*7) ផែនការតាមដានបន្ត ៖* អ្នកផ្តល់សេវាថែទាំសុខភាព ណែនាំយុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ឱ្យស្គាល់ក្រុមគាំទ្រមិត្ត និង/ឬអង្គការក្រៅរដ្ឋាភិបាល ដើម្បីជួយក្នុងអំឡុងពេលវគ្គអប់រំ និងតាមដានបន្តនៅក្នុងដំណាក់កាលក្រោយអន្តរកាល ។

## 4.2.2. ជំហានសម្រាប់ថែរក្សាយុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ ក្នុងសេវា ART កុមារ




*រូបភាពទី 2: តារាងលំហូរនៃយុទ្ធសាស្ត្រថែរក្សា*

សម្រាប់យុទ្ធសាស្ត្រថែរក្សា សកម្មភាពសំខាន់ៗនៅទីតាំង PAC មានដូចខាងក្រោម ៖

1) *ការកត់ត្រា និងការត្រួតពិនិត្យតាមដាននិងវាយតម្លៃ ៖* អ្នកផ្តល់សេវាសុខភាព ពិនិត្យឡើងវិញ និងធ្វើចំណាត់ថ្នាក់អ្នកជំងឺដោយផ្អែកលើចំណេះដឹង រូបមន្តព្យាបាលរបស់ពួកគេ ជាធនធានដែលត្រូវការ ទៅតាមអាយុនិងផែនការអន្តរកាលរបស់បុគ្គលនោះ ។ ការធ្វើចំណាត់ថ្នាក់អ្នកជំងឺ ជួយអ្នកផ្តល់សេវាសុខភាពរៀបចំផែនការដើម្បីគាំទ្រអ្នកជំងឺទាំងនោះ ។

2) *ផ្តួចផ្តើមផែនការថែរក្សា៖* អ្នកផ្តល់សេវាសុខភាពធ្វើការជាមួយយុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ និង/ឬអាណាព្យាបាល ដើម្បីផ្តួចផ្តើមផែនការថែរក្សា ។ ផែនការថែរក្សានេះ អាចជាមគ្គុទេសមួយសម្រាប់អ្នកជំងឺ អាណាព្យាបាល និងអ្នកផ្តល់សេវាសុខភាព ដើម្បីស្វែងយល់ពីតម្រូវការ រៀបចំផែនការការគាំទ្រ និងតាមដានបន្តលើអ្នកជំងឺ ។

3) *ផ្តល់ប្រឹក្សា ការគាំទ្រនិងការអប់រំផ្នែកចិត្តសង្គម៖* អ្នកផ្តល់សេវាសុខភាពផ្តល់ការប្រឹក្សាពិសេសដល់អ្នកជំងឺតាមតម្រូវការ រួមជាមួយឬក្នុងអំឡុងពេលវគ្គអប់រំសុខភាព (រំលឹកកម្រិតទី ១ និងទី ២ ផ្តល់ដោយយឺតៗ) និងជួយដល់ការបង្ហាញស្ថានភាពមេរោគអេដស៍ និងពង្រឹងបំណិនជីវិត) ។

4) *សេវាមេត្រីភាពយុវជន៖* អ្នកផ្តល់សេវាសុខភាពជានាបរិយាកាស សេវាមេត្រីភាពយុវជនសម្រាប់យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ ជាពិសេស អ្នកដែលត្រូវការការគាំទ្រពិសេស (ឧទា. ការអភិវឌ្ឍសតិបញ្ញាខ្សោយ, យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ដែលមានជំងឺអូទីហ្សឹម ជាដើម) ។ អ្នកផ្តល់សេវាសុខភាព ពិចារណាផ្តួចផ្តើមក្រុមគាំទ្រពីមិត្តភក្តិ ឬតភ្ជាប់ទៅនឹងសេវារបស់អង្គការក្រៅរដ្ឋាភិបាល ដែលអាចផ្តល់ការគាំទ្របន្ថែម (ឧទា. ការគាំទ្រផ្នែកផ្លូវចិត្តសង្គម, ការដឹកជញ្ជូន ។ល។) ។

5) *ក្នុងករណីអ្នកជំងឺស្នើសុំផ្ទេរចេញ,* អ្នកផ្តល់សេវាសុខភាព វាយតម្លៃ និងរៀបចំអ្នកជំងឺដើម្បីផ្ទេរទៅ ART សម្រាប់មនុស្សពេញវ័យ (*ធ្វើតាមជំហាន ៤.២.១*) ។ ប្រសិនបើគ្មានការស្នើសុំផ្ទេរចេញទេ យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ គួរតែបន្តស្ថិតនៅក្នុងគ្លីនិក PAC ។ នៅពេលយុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ ឈានដល់អាយុ ១៥ ឆ្នាំ អ្នកផ្តល់សេវាសុខភាព គួរតែប្តូរអត្តសញ្ញាណរបស់គាត់ និងរក្សាទុកប្រវត្តិរូបរបស់ពួកគេនៅក្នុងបញ្ជីឈ្មោះមនុស្សពេញវ័យ ។

## 4.3. ក្រោយពេលអន្តរកាល

### 4.3.1. *ជំហានសម្រាប់ផ្ទេរចេញទៅសេវា ART សម្រាប់មនុស្សពេញវ័យ*

បន្ទាប់ពីយុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ ផ្ទេរចេញទៅកាន់ទីតាំង ART សម្រាប់មនុស្សពេញវ័យ មានជំហានសំខាន់ៗមួយចំនួនដែលត្រូវអនុវត្ត ៖

a) *ការកត់ត្រា និង ការតាមដាន និង វាយតម្លៃ ៖* អ្នកផ្តល់សេវាសុខភាពនៅទីតាំង ART សម្រាប់មនុស្សពេញវ័យ ពិនិត្យមើលឯកសារដែលបានបញ្ជូនពីទីតាំង PAC ដែលបញ្ជាក់ប្រវត្តិនៃការព្យាបាលរបស់អ្នកជំងឺ ។ បន្ទាប់មក កត់ត្រាប្រវត្តិនៃការព្យាបាលនៅក្នុងទម្រង់នៃកំណត់ត្រារបស់មនុស្សពេញ-វ័យ ។ អ្នកផ្តល់សេវាសុខភាព ធ្វើការតាមដានបន្តជាមួយ PAC សម្រាប់ព័ត៌មានបន្ថែមតាមតម្រូវការ ។

b) *ការផ្តល់ប្រឹក្សា និងការអប់រំ ៖* អ្នកផ្តល់សេវាសុខភាពបង្កើតទំនាក់ទំនងជាមួយយុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ដែលទើបនឹងផ្ទេរមកថ្មីៗ, ផ្តល់ដល់ពួកគេនូវការអប់រំសុខភាពកម្រិតទី២ និងកម្រិតទី៣ [ពោលគឺ MMD, ជំងឺឆ្លងផ្សេងទៀតក្នុងពេលតែមួយ (ជំងឺរបេង និង ជំងឺថ្លើម), ម=ម)] ។

c) *សេវាមេត្រីភាពយុវជន ៖* អ្នកផ្តល់សេវាសុខភាព រៀបចំឱ្យមានបរិយាកាសមេត្រីភាពយុវវ័យ និងភ្ជាប់ យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ ជាមួយក្រុមគាំទ្រមិត្តភក្តិ ឬអង្គការក្រៅរដ្ឋាភិបាល (ពោលគឺ ម៉ោងពិគ្រោះជំងឺអាចបត់បែន, គ្លីនិកសម្រាប់តែយុវវ័យ, ក្រុមគាំទ្រមិត្តភក្តិ, ការគាំទ្រសម្រាប់ការដឹកជញ្ជូន, សម្ភារ IEC, និងការប្រើសារតាមទូរស័ព្ទសម្រាប់គាំទ្រ និងភ្ជាប់ទៅនឹងប្រព័ន្ធផ្សព្វផ្សាយសង្គមផ្សេងៗទៀតដែលបង្កើតឡើងដោយផ្នែក ប្រាស្រ័យទាក់ទងសម្រាប់ការផ្លាស់ប្តូរឥរិយាបទ-NCHADS សម្រាប់ព័ត៌មានបន្ថែមអំពីមេរោគអេដស៍) ។

d) *លទ្ធផលសុខភាព ៖* អ្នកផ្តល់សេវាសុខភាព បន្តការត្រួតពិនិត្យតាមដាន និងវាយតម្លៃលទ្ធផលសុខ-ភាពរបស់យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ និងឱ្យអាណាព្យាបាលចូលរួមនៅពេលត្រូវការ ។

### 4.3.2. ជំហានសម្រាប់ការថែរក្សានៅសេវា PAC កុមារ

1) *ការកត់ត្រា និងការត្រួតពិនិត្យតាមដាននិងវាយតម្លៃ។* អ្នកផ្តល់សេវាសុខភាពធ្វើបច្ចុប្បន្នភាពកំណត់ត្រារបស់អ្នកជំងឺផ្អែកលើអាយុរបស់ពួកគេ ។ នៅពេលយុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ ឈានដល់អាយុ ១៥ ឆ្នាំ អ្នកផ្តល់សេវាសុខភាពធ្វើបច្ចុប្បន្នភាពអត្តសញ្ញាណរបស់យុវវ័យ និងរក្សាទុកប្រវត្តិរូបរបស់គាត់ក្នុងបញ្ជីឈ្មោះមនុស្សពេញវ័យ ។

2) *ផែនការតាមដានបន្តការថែរក្សា ៖* អ្នកផ្តល់សេវាសុខភាពបន្តតាមដានបន្តការថែរក្សាជាមួយយុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ និង/ឬអាណាព្យាបាលរបស់ពួកគេ ។

3) *ការផ្តល់ប្រឹក្សានិងការអប់រំ ៖* អ្នកផ្តល់សេវាសុខភាពបន្តផ្តល់ការអប់រំសុខភាពកម្រិតទី២ និងកម្រិតទី៣ [MMD, ជំងឺឆ្លងផ្សេងទៀតក្នុងពេលតែមួយ (ជំងឺរបេង និង ជំងឺថ្លើម), ម=ម)] ផ្អែកលើតម្រូវការរបស់អ្នកជំងឺម្នាក់ៗ/ក្រុម (សម្រាប់ព័ត៌មានលម្អិត, *សូមមើលការគាំទ្រផ្នែកការប្រឹក្សានិងតួនាទី និងទំនួលខុសត្រូវរបស់យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ អាណាព្យាបាល និងអ្នកផ្តល់សេវាថែទាំសុខភាព ។*

4) *សេវាមេត្រីភាពយុវជន ៖* អ្នកផ្តល់សេវាសុខភាព រៀបចំឱ្យមានបរិយាកាសមេត្រីភាពយុវវ័យ និងភ្ជាប់យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ ជាមួយក្រុមគាំទ្រមិត្តភក្តិ ឬអង្គការក្រៅរដ្ឋាភិបាល (ពោលគឺ ម៉ោងពិគ្រោះជំងឺអាចបត់បែន, គ្លីនិកសម្រាប់តែយុវវ័យ, ក្រុមគាំទ្រមិត្តភក្តិ, ការគាំទ្រសម្រាប់ការដឹកជញ្ជូន, សម្ភារ IEC, និងការប្រើសារតាមទូរស័ព្ទសម្រាប់គាំទ្រ និងភ្ជាប់ទៅនឹងប្រព័ន្ធផ្សព្វផ្សាយសង្គមផ្សេងៗទៀតដែលបង្កើតឡើងដោយផ្នែក ប្រាស្រ័យទាក់ទងសម្រាប់ការផ្លាស់ប្តូរឥរិយាបទ-NCHADS សម្រាប់ព័ត៌មានបន្ថែមអំពីមេរោគអេដស៍) ។

5) *លទ្ធផលសុខភាព ៖* អ្នកផ្តល់សេវាសុខភាពបន្តត្រួតពិនិត្យតាមដាន និងវាយតម្លៃលទ្ធផលសុខភាពរបស់យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ និងមានការចូលរួមពីអាណាព្យាបាលនៅពេលត្រូវការ




*រូបភាពទី 3: សង្ខេបដំណើរការអន្តរកាលរបស់យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍*

# 5. ការគាំទ្រផ្នែកផ្តល់ប្រឹក្សា

## 5.1. ជំហានដើម្បីផ្តល់ប្រឹក្សា

ការផ្តល់ប្រឹក្សាត្រឹមត្រូវ (ជាបុគ្គល ឬជាក្រុម) គួរតែត្រូវបានផ្តល់ជូនដល់យុវវ័យ និងគ្រួសាររបស់ពួកគេក្នុងអំឡុងពេលមុនអន្តរកាល ។ ការផ្តល់ប្រឹក្សាគួរតែរួមបញ្ចូលការវាយតម្លៃទស្សនៈរបស់ពួកគេចំពោះអន្តរកាល នៅពេលដែលពួកគេត្រៀមខ្លួនរួចរាល់ តើអ្នកណានិងរបៀបគាំទ្រអន្តរកាល ។ ខាងក្រោមនេះ គឺជាជំហានសំខាន់ៗ ៖

**ជំហានទី ១** - ផ្តល់ប្រឹក្សាដល់អាណាព្យាបាលទាក់ទងនឹងប្រធានបទ៖ ទីមួយ៖ ការបង្ហាញស្ថានភាពមេរោគអេដស៍ជាបឋម (ប្រសិនបើមិនទាន់បានបង្ហាញ), ទីពីរ៖ ការយល់ដឹងអំពីការប្រកាន់ខ្ជាប់តាមការព្យាបាលដោយ ARV គួរតែត្រូវបានលើកឡើងផងដែរ ដើម្បីគាំទ្រនិងណែនាំអាណាព្យាបាលអំពីមាគ៌ាដែលជួយយុវវ័យគ្រប់គ្រងការណាត់ជួបនៅ ART ដោយខ្លួនឯងនៅពេលណាមួយ ។ ការវាយតម្លៃមុនពេលអន្តរកាលត្រូវបានធ្វើឡើងដើម្បីស្វែងយល់ពីកិច្ចការសំខាន់ៗ ដូចជា របៀបធ្វើការណាត់ជួបនៅ ART, ស្វែងរកការគាំទ្រពីអ្នកផ្តល់សេវាសុខភាព និងអ្នកផ្សេងទៀត, គ្រប់គ្រងថ្នាំ ARV របស់ពួកគេ និងទទួលខុសត្រូវចំពោះសុខភាពខ្លួនឯងនិងសុខភាពអ្នកដទៃ ។

**ជំហានទី ២** - លើកទឹកចិត្តអ្នកជំងឺនិងអាណាព្យាបាលឱ្យបំពេញតួនាទីនិងទំនួលខុសត្រូវរបស់ពួកគេ *(សូមមើលផ្នែកទី VI. តួនាទីនិងទំនួលខុសត្រូវរបស់យុវវ័យដែលរស់នៅជាមួយជាមួយមេរោគអេដស៍, អាណាព្យាបាល និងអ្នកផ្តល់សេវាសុខភាព)*។

**ជំហានទី ៣** - អនុញ្ញាតឱ្យយុវវ័យដែលរស់នៅជាមួយមេរោគអេដស៍កំណត់ទីតាំង សេវាART សម្រាប់មនុស្សពេញវ័យ ដែលគាត់/នាងយល់ថា ងាយស្រួល ។ ដូច្នេះ អ្នកផ្តល់សេវាថែទាំសុខភាពកុមារគួរផ្តល់ព័ត៌មានលម្អិតអំពីទីតាំងដែលសមស្របសម្រាប់យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ ជាកន្លែងដែលអាចទទួលបានការគាំទ្រចាំបាច់បន្ថែមពីអង្គការមិនមែនរដ្ឋាភិបាលផងដែរ (សម្រាប់ជម្រើសផ្ទេរចេញ សូមមើលចំណុច B.2.) ។

**ជំហានទី ៤** - វាយតម្លៃចំណេះដឹងអំពីមេរោគអេដស៍, ឆន្ទៈក្នុងការបង្ហាញមេរោគអេដស៍ និងកត្តាផ្សេងៗទៀតមួយជំហានម្តងៗ (សូមមើលឧបសម្ព័ន្ធទី ៣ ៖ ការវាយតម្លៃចំណេះដឹងសម្រាប់ត្រៀមអន្តរកាល) បន្ទាប់មក ធ្វើការសន្និដ្ឋាន ។ ប្រសិនបើយុវវ័យដែលរស់នៅជាមួយមេរោគអេដស៍និងអាណាព្យាបាលមិនទាន់ត្រៀមខ្លួនរួចរាល់នៅឡើយទេ សូមធ្វើការវាយតម្លៃនិងផ្តល់វគ្គប្រឹក្សាឡើងវិញយ៉ាងតិចរៀងរាល់ ៣ ទៅ ៦ ខែម្តង ។ *វាជាការសំខាន់ណាស់ដែលត្រូវកត់សម្គាល់ថា ការវាយតម្លៃមិនគួរដាក់សម្ពាធលើយុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ និងអាណាព្យាបាលអំពីការផ្ទេរចេញនោះទេ សំខាន់គឺការសម្រេចចិត្តដែលធ្វើឡើងដោយខ្លួនពួកគេផ្ទាល់ផ្អែកលើព័ត៌មានដែលមាន និងក្រោមកាតព្វកិច្ចថែទាំរបស់អ្នកផ្តល់សេវាសុខភាពក្នុងការគាំទ្រដល់អន្តរកាលដោយរលូន ។*

ដំហានទី ៥ - ការគាំទ្រពីអ្នកពាក់ព័ន្ធផ្សេងទៀត (កម្មវិធីឬអ្នកផ្តល់សេវា) ដើម្បីដោះស្រាយតម្រូវការត្រៀមខ្លួនរបស់យុវវ័យ គួរតែផ្តោតលើការចូលរួមពីឪពុកម្តាយ ក្នុងករណីអាណាព្យាបាល ឬឪពុកម្តាយចិញ្ចឹម ទាំងនៅក្នុងសហគមន៍ ឬក្នុងមណ្ឌលកុមារកំព្រា ក៏ដូចជាសមាជិកគ្រួសារ និងមិត្តភក្តិ នៅពេលណាអាចអនុវត្តទៅបាន[12] ។ បទពិសោធន៍ពីទីតាំង ART និងអង្គការក្រៅរដ្ឋាភិបាល និងរបកគំហើញពីសហគមន៍ក៏បានបញ្ជាក់ពីភ័ស្តុតាងស្រដៀងគ្នានេះដែរ ។

## 5.2. កម្រិតចំណេះដឹងសម្រាប់យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ ផ្អែកតាមអាយុ

ខាងក្រោមនេះគឺប្រភេទចំណេះដឹងសម្រាប់វគ្គក្រុម ឬវគ្គបុគ្គលដែលអាចមាន និងការជ្រើសរើសយកប្រតិទិន ដែលសមស្របមួយសម្រាប់ទាំងអ្នកផ្តល់សេវាសុខភាព និងយុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ ។ **សូមមើលឧបសម្ព័ន្ធទី ២ ផ្អែកទី II ។**

1) ចំណេះដឹងជាមូលដ្ឋាន (កម្រិតទី I)៖ ចំណេះដឹងជាមូលដ្ឋាននេះត្រូវបានផ្តល់ដោយអ្នកផ្តល់សេវាសុខភាពនៅឯទីតាំង PAC មុនពេលចាប់ផ្តើមរយៈពេលត្រៀមអន្តរកាល ។ ទោះបីយ៉ាងណាក្តី កម្រិតនៃការយល់ដឹងអាចមានភាពខុសគ្នាពីអ្នកជំងឺម្នាក់ទៅអ្នកជំងឺម្នាក់ទៀត ។ ដូច្នេះ អ្នកផ្តល់សេវាសុខភាពគួររំលឹកឡើងវិញ និងផ្តល់ចំណេះដឹងបន្ថែមដល់យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ ។ *(សូមមើលតារាងទី ១ ៖ កម្រិតចំណេះដឹងដែលបានស្នើឡើងសម្រាប់យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ផ្អែកតាមអាយុរបស់ពួកគេ) ។*

2) ចំណេះដឹងទីពីរ (កម្រិតទី II)៖ កម្រិតចំណេះដឹងផ្អែកខាងលើនេះ ដូចដែលបានរៀបរាប់នៅក្នុងតារាងទី ៤ គួរតែត្រូវបានផ្តល់ជូនក្នុងអំឡុងពេលរៀបចំការផ្ទេរចេញ ក៏ដូចជាការរក្សាទុកដោយផ្អែកលើការវាយតម្លៃដោយអ្នកផ្តល់សេវាសុខភាព ។ អ្នកផ្តល់សេវាសុខភាពអាចសម្រេចចិត្តជ្រើសរើសវគ្គដែលសមស្របទៅនឹងការទទួលយកបានរបស់អ្នកជំងឺ ***(សូមមើលតារាងទី ១ ៖ កម្រិតចំណេះដឹងដែលបានស្នើឡើងសម្រាប់យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ ផ្អែកតាមអាយុ)*** ។ អ្នកផ្តល់សេវាសុខភាពគួរធានាថា ចំណេះដឹងត្រូវបានវាយតម្លៃយ៉ាងល្អក្នុងអំឡុងពេលត្រៀមអន្តរកាល នៅក្នុងវគ្គផ្តល់ប្រឹក្សា ។

3) ចំណេះដឹងទីបី (កម្រិតទី III): ចំណេះដឹងកម្រិតខ្ពស់នេះ គួរតែសមស្របសម្រាប់រយៈពេលក្រោយអន្តរកាល សម្រាប់ការថែរក្សាទុកដាក់ ឬការផ្ទេរចេញ ។ ចំណេះដឹងនេះគួរតែត្រូវបានផ្តល់ជូនអ្នកជំងឺដែលមានអាយុចាប់ពី ១៥ ឆ្នាំឡើងទៅ ។

[12] Icard LD, Jemmott JB, Carty C, O'Leary A, Sidloyi L, Hsu J, Tyler J, Martinez O. Retention of South African adolescents in a 54-month longitudinal HIV risk reduction trial. Prevention Science. 2017 Jul 1;18(5):534-40.

*តារាងទី 1:* កម្រិតចំណេះដឹងដែលស្នើឡើងសម្រាប់យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ ផ្អែកតាមអាយុ

| ប្រភេទក្រុមអាយុ | ត្រៀមអន្តរកាល | ក្នុងអំឡុងពេលអន្តរកាល | | ក្រោយអន្តរកាល | |
|---|---|---|---|---|---|
| | | ការថែរក្សាទុក | ការផ្ទេរចេញ | ការថែរក្សាទុក | ការផ្ទេរចេញ |
| 10 - 12 ឆ្នាំ | I | I ឬ II | - | - | - |
| 13 - 14 ឆ្នាំ | I + II | II (I+II) | II | II | - |
| > 15 ឆ្នាំ * | - | - | - | III (I+II+III) | III |
| ** ត្រូវតែធ្វើឡើងឡើងវិញ កម្រិតទី I, II ប្រសិនបើពួកគេមិនដែលបានទទួលកម្រិតទាំងនោះ ។* | | | | | |

| ប្រភេទ |
|---|
| **ចំណេះដឹងមូលដ្ឋាន (កម្រិតទី I):** ចំណេះដឹងអំពីអនាម័យផ្ទាល់ខ្លួន ចំណេះដឹងអំពីមេរោគអេដស៍ជាមូលដ្ឋាន រៀបចំសម្រាប់បង្ហាញពីស្ថានភាពមេរោគអេដស៍ |
| **ចំណេះដឹងទីពីរ (កម្រិតទី II):** ជំងឺឱកាសនិយម, ការបង្ហាញពីស្ថានភាពមេរោគអេដស៍, រូបមន្តថ្នាំ ARV, EAC (ការគោរពខ្ជាប់ខ្លួនតាមការព្យាបាលដោយខ្លួនឯង), សុខភាពផ្លូវភេទ និងសុខភាពបន្តពូជ, ជំងឺឆ្លងតាមការរួមភេទ (ជំងឺកាមរោគ), ផែនការគ្រួសារ, និងការបង្ការវិជ្ជមាន ។ |
| **ចំណេះដឹងទីបី (កម្រិតទី III): MMD, ជំងឺឆ្លងផ្សេងទៀតក្នុងពេលតែមួយ (ជំងឺរបេង និង ជំងឺថ្លើម), និង ម=ម)** |

ការលើកកម្ពស់ចំណេះដឹងជាមូលដ្ឋានក្នុងចំណោមយុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ នឹងធ្វើឱ្យអន្តរកាល កាន់តែជោគជ័យថែមទៀត ។ តាមរយៈការដាក់តម្រូវចំណេះដឹងនិងជំនាញរបស់យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍លើការថែទាំអេដស៍, ការគ្រប់គ្រងឱសថ, ការគ្រប់គ្រងការណាត់ជួប, ឥរិយាបថកាត់បន្ថយគ្រោះថ្នាក់ ត្រូវបានបង្ហាញថា ជួយដល់ពួកគេដើម្បីត្រៀមខ្លួនសម្រាប់អន្តរកាល ។ ខាងក្រោមនេះ គឺជាចំណុចពិចារណាសំខាន់ៗសម្រាប់អ្នកផ្តល់សេវាសុខភាពដែលត្រូវអនុវត្តតាមក្នុងការផ្តល់វគ្គអប់រំសុខភាពនៅក្នុងគ្លីនិក PAC ។

i. ផ្តួចផ្តើមនិងរៀបចំការប្រជុំជាប្រចាំ ជាពិសេស ដោយផ្អែកលើកាលវិភាគណាត់ជួបសម្រាប់ ARV (រៀងរាល់ ២ ឬ ៣ ខែម្តង)

ii. សម្របសម្រួល/បង្កើតបណ្តាញមួយសម្រាប់ផ្តល់ប្រឹក្សាជាក្រុមដោយស្ម័គ្រចិត្ត ។ បើអាចធ្វើបាន ជួយពួកគេ រៀបចំខ្លួនសម្រាប់ផែនការអន្តរកាល ។

iii. កំណត់ពីតម្រូវការគ្រប់គ្រងខ្លួនឯងឬគ្រប់គ្រងក្រុមរបស់យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ និងអ្នកថែទាំរបស់ពួកគេ ។

iv. រៀបចំផែនការវគ្គប្រឹក្សាមួយដំហានម្តងៗ និងប្រកបដោយមិត្តភាពយុវវ័យ ។ ខាងក្រោមនេះ គឺជាវគ្គស្នូលដែលមានរចនាសម្ព័ន្ធ ដែលចាំបាច់សម្រាប់យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍, មិត្តភក្តិ និងអាណាព្យាបាលរបស់ពួកគេ ៖

វាអាចជាប្រធានបទរសើបខាងវប្បធម៌សម្រាប់យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ ។ ត្រូវប្រាកដថា ចំណេះដឹងជាមូលដ្ឋានអំពីបញ្ហា មិនមានន័យថា យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍កំពុងយកចិត្តទុកដាក់ចំពោះបញ្ហាណាមួយក្នុងពេលនេះនោះឡើយ សូមកុំវិនិច្ឆ័យទៅលើអ្នកចូលរួម ។ ត្រូវបញ្ជាក់ឱ្យច្បាស់ចំពោះពួកគេថា បញ្ហានេះច្រើនតែកើតឡើងជាទូទៅចំពោះមនុស្សពេញវ័យ ខណៈដែលពួកគេមានចំណេះដឹងជាមូលដ្ឋានខ្លះប៉ុណ្ណោះអំពីបញ្ហានេះ ។

ក្នុងចំណោមប្រធានបទទាំងនេះ អាចមានប្រធានបទរងមួយចំនួនទៀត អាស្រ័យលើក្រុមអាយុកំណត់ និងចំណាប់អារម្មណ៍ផ្សេងៗ ។ អ្នកផ្តល់ប្រឹក្សាគួរតែប្រើសម្ភារចម្រុះ ដូចជា សម្ភារបោះពុម្ព សោតទស្សន៍ និងវីដេអូ ដើម្បីជួយដល់ការពិភាក្សា និងពង្រីកវគ្គប្រសិនបើចាំបាច់ ។ សូមផ្តល់ចំណេះដឹងជាមូលដ្ឋានអំពីរបៀបស្វែងរកឯកសារសិក្សាបន្ថែម តាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គមនិងបណ្តាញអង្គការមិនមែនរដ្ឋាភិបាល ផ្សេងៗទៀត ។

លើកទឹកចិត្តមិត្តអ្នកបង្ហាត់បង្ហាញក្នុងចំណោមអ្នកដែលសកម្ម និងដែលគេជឿទុកចិត្ត ។ ដើម្បីរក្សាការសម្ងាត់ អ្នកផ្តល់ប្រឹក្សាគួរតែផ្តល់ឱកាសមិត្តភក្តិ ឬយុវវ័យដែលរស់នៅជាមួយមេរោគអេដស៍នីមួយៗ ដើម្បីជជែកគ្នានៅទីកន្លែងដែលមានលក្ខណៈឯកជន និងមានសុវត្ថិភាព ។

## 6. តួនាទីនិងទំនួលខុសត្រូវរបស់យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ អាណាព្យាបាល និងអ្នកផ្តល់សេវាសុខភាព

ផ្នែកនេះបង្ហាញអំពីតួនាទីនិងទំនួលខុសត្រូវរបស់យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ អាណាព្យាបាល និងអ្នកផ្តល់សេវាសុខភាពនៅក្នុងគ្រប់ដំណាក់កាល ។ បន្ថែមលើការថែទាំនិងព្យាបាលជំងឺអេដស៍ អ្នកផ្តល់សេវាគួរតែមានចំណេះដឹងច្បាស់អំពីសុខភាពផ្លូវភេទនិងសុខភាពបន្តពូជ ជំងឺកាមរោគ ផែនការគ្រួសារ ការបង្ការវិជ្ជមានបំណិនជីវិត ជំងឺឆ្លងផ្សេងទៀតក្នុងពេលតែមួយ (ជំងឺរបេង និង ជំងឺថ្លើម), និង ម=ម) ដើម្បីផ្តល់ការអប់រំ/ការប្រឹក្សាដល់យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ ពីកម្រិតទី I ដល់ទី III ។

## 6.1. ការត្រៀមអន្តរកាល

*តារាង 2:* ម៉ាទ្រីសតួនាទី និងទំនួលខុសត្រូវសម្រាប់ត្រៀមអន្តរកាលនៅទីតាំង PAC

| ក្រុមគន្លឹះ | តួនាទីនិងទំនួលខុសត្រូវសម្រាប់ត្រៀមអន្តរកាលនៅទីតាំង PAC |
|---|---|
| ALHIV | 1) ចូលរួមក្នុងវគ្គប្រឹក្សា តាមការណាត់ជួបដោយអ្នកផ្តល់សេវាសុខភាព/អ្នកផ្តល់ប្រឹក្សា<br>2) ស្តាប់ដោយយកចិត្តទុកដាក់, សួររកការបំភ្លឺ និងស្វែងយល់ពីដំណើរការអន្តរកាល ទាំងការផ្ទេរចេញទៅទីតាំង ART សម្រាប់មនុស្សពេញវ័យ ឬការថែរក្សាទុកក្នុងទីតាំង ART សម្រាប់កុមារ |
| អាណាព្យាបាល | 1) ផ្តល់ការគាំទ្រផ្នែកផ្លូវកាយ ផ្លូវចិត្ត និងហិរញ្ញវត្ថុ ដល់យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍នៅក្នុងដំណើរការត្រៀមអន្តរកាល (ឧទា. អមដំណើរយុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ ទៅកាន់ទីតាំង PAC, លើកទឹកចិត្តយុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ ឱ្យសួរសំណួរ ។ល។)<br>2) ស្តាប់ដោយយកចិត្តទុកដាក់, សួររកការបំភ្លឺ និងស្វែងយល់ពីដំណើរការអន្តរកាល ទាំងការបញ្ជូនទៅទីតាំង ART សម្រាប់មនុស្សពេញវ័យ ឬការថែរក្សាទុកនៅក្នុងទីតាំង ART ដដែល ។<br>3) លើកទឹកចិត្តយុវវ័យដែលរស់នៅជាមួយមេរោគអេដស៍របស់ពួកគេ នៅក្នុងរយៈពេលត្រៀមអន្តរកាល និងពន្យល់ដល់ពួកគេឱ្យយល់ពីដំណើរការអន្តរកាស ។<br>4) ដឹងអំពីលក្ខខណ្ឌតម្រូវនិងឯកសារចាំបាច់ដើម្បីទៅកាន់ទីតាំង ART សម្រាប់មនុស្សពេញវ័យ ។<br>5) ស្វែងយល់និងរៀបចំការគាំទ្រដល់កូនៗរបស់ពួកគេក្នុងអំឡុងពេលអន្តរកាល ។ |
| អ្នកផ្តល់សេវាសុខភាព | 1) ត្រូវមានចំណេះដឹង និងឆ្លើយតបទៅនឹងគ្រប់ជំហាននៃអន្តរកាល និងឧបករណ៍ត្រូវការ<br>2) ធានាថា យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ ត្រូវបានផ្តល់ព័ត៌មានច្បាស់លាស់អំពីជំហាននីមួយៗ និងជួយរៀបចំផែនការបុគ្គលដែលចាំបាច់សម្រាប់ការថែរក្សាទុក និងការផ្ទេរចេញ ។<br>3) ប្រើប្រាស់លក្ខណវិនិច្ឆ័យនៃភាពសមស្រប និងការវាយតម្លៃ (ទិន្នន័យមូលដ្ឋាន និងចុងគ្រា) ដើម្បីកំណត់ពីចំណេះដឹង ឥរិយាបថ និងការប្រកាន់ខ្ជាប់តាម ARV មុន និងក្នុងអំឡុងពេលដំណើរការអន្តរកាល<br>4) វាយតម្លៃតម្រូវការរបស់យុវវ័យ និងអ្នកថែទាំរបស់ពួកគេ បន្ទាប់មក ជួយពួកគេក្នុងការរៀបចំផែនការអន្តរកាលសម្រាប់យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ ដោយផ្អែកលើតម្រូវការរបស់ពួកគេ ។ សម្គាល់ ៖ ផែនការត្រូវតែត្រូវបានរៀបចំឡើងទៅតាមសមត្ថភាពធនធានរបស់បុគ្គលជាយុវវ័យម្នាក់ៗ ដូចជា ផ្លូវកាយ ផ្លូវចិត្ត សង្គម ស្មារតី និងសុខភាព និងសុខុមាលភាពរបស់ពួកគេ ។ |

## 6.2. ក្នុងអំឡុងពេលអន្តរកាល

### 6.2.1. ការរៀបចំផ្ទេរចេញ

**តារាងទី 3**: ម៉ាទ្រីសតួនាទីនិងទំនួលខុសត្រូវសម្រាប់ការរៀបចំផ្ទេរចេញនៅទីតាំង PAC

| ក្រុមសំខាន់ | តួនាទីនិងទំនួលខុសត្រូវសម្រាប់ការរៀបចំផ្ទេរចេញនៅទីតាំង PAC |
|---|---|
| ALHIV | 1) សិក្សា និងសួរដោយយឺតៗ និងផ្តល់ព័ត៌មានប្រកបដោយន័យស្ថាបនា ៖<br>• របៀបដែលកុមារចង់ធ្វើអ្វីៗដោយខ្លួនឯង (ពោលគឺ ថែទាំសុខភាពខ្លួនឯង គ្រប់គ្រងថ្នាំ ARV (ចំនួនថ្នាំ ARV ដែលបានលេប, ការរំលឹកការលេបថ្នាំ ARV, ការរក្សាទុកថ្នាំ ARV ដោយសុវត្ថិភាព, និងការតាមដានមើលផលរំខានរបស់ថ្នាំ)<br>• របៀបយកថ្នាំរបស់ពួកគេទៅតាមខ្លួន ប្រសិនបើពួកគេទៅឆ្ងាយពីផ្ទះរបស់ពួកគេ (ចំនួនថ្ងៃធ្វើដំណើរ, ចំនួនថ្នាំ ARV បូក ២ ថ្ងៃទៀត ។ល។)<br>• វិធីកែលម្អគុណភាពជីវិត (ពោលគឺ អនាម័យរាងកាយក្នុងសកម្មភាពប្រចាំថ្ងៃ, តុល្យភាពរបបអាហារ, ការហាត់ប្រាណគ្រប់គ្រាន់, ការជៀសវាងទម្លាប់ដែលបង្កគ្រោះថ្នាក់ និងការគ្រប់គ្រងស្ត្រេស)<br>2) កែលម្អចំណេះដឹងរបស់ពួកគេ ដោយឱ្យពួកគេពួកគេចូលរួមជាមួយក្រុមគាំទ្រប្រសិនបើមាន ដើម្បីរៀនសូត្រពីមិត្តភក្តិដទៃទៀត ដែលអាចធ្វើបានប្រសើរជាក្នុងការប្រកាន់ខ្ជាប់តាមការព្យាបាល ឬស្តាប់អ្នកផ្តល់ប្រឹក្សាដោយប្រុងប្រយ័ត្ន ឬសួរសំណួរប្រសិនបើពួកគេចង់ស្វែងយល់បន្ថែម ។<br>3) រៀនពីជំនាញដោះស្រាយបញ្ហា ដូចជារបៀបសម្គាល់ជំងឺរបស់ពួកគេ, តើត្រូវពិគ្រោះយោបល់/ទាក់ទងជាមួយអ្នកណានៅពេលគាត់ជួបប្រទះបញ្ហាប្រឈម និងស្វែងរកដំបូន្មានបន្ថែមពីអ្នកផ្តល់សេវាសុខភាពប្រសិនបើចាំបាច់, អ្វីដែលត្រូវធ្វើដើម្បីដោះស្រាយបញ្ហា/ជំងឺរបស់ពួកគេ ។<br>4) ស្វែងយល់ពីលក្ខខណ្ឌតម្រូវការនិងឯកសារចាំបាច់ ដើម្បីចូលទៅកាន់ទីតាំង ART សម្រាប់មនុស្សពេញវ័យ<br>5) ការចូលទៅទីតាំង ART ថ្មីសម្រាប់មនុស្សពេញវ័យ តាមកាលបរិច្ឆេទ/កាលវិភាគដែលបានណែនាំឱ្យបានទាន់ពេលវេលា<br>6) បញ្ជាក់ឱ្យច្បាស់ថា ពួកគេមិនចាំបាច់រង់ចាំរហូតដល់ពួកគេបញ្ចប់ថ្នាំ ARV ទាំងអស់ មុនពេលត្រឡប់មកវិញនោះទេ ។ |

| ក្រុមសំខាន់ | តួនាទីនិងទំនួលខុសត្រូវសម្រាប់ការរៀបចំផ្ទេរចេញនៅទីតាំង PAC |
|---|---|
| អាណាព្យាបាល | 1) ផ្តល់ការគាំទ្រផ្នែកផ្លូវកាយ, ផ្លូវចិត្ត និងហិរញ្ញវត្ថុដល់យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ក្នុងដំណើរការអន្តរកាល ពោលគឺ គឺលើកទឹកចិត្តឱ្យយុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ ស្រឡាញ់សុខភាពរបស់គាត់ និងទទួលខុសត្រូវចំពោះសុខភាពផ្ទាល់ខ្លួនគាត់ និងសុខភាពរបស់សហគមន៍ទាំងមូល ។ *សូមមើលការពង្រឹងការផ្តល់ប្រឹក្សា ការលេបថ្នាំត្រឹមត្រូវ ទៀងទាត់ និងជាប់លាប់ និងសម្ភារផ្តល់ប្រឹក្សាសម្រាប់ ចំនួនមេរោគ៖ "មិនអាចរាប់បាន = មិនអាចចម្លងបាន (the Undetected=Uninfected) សម្រាប់សារលម្អិតបន្ថែម ។*<br>2) ផ្តល់ការគាំទ្រដល់យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ ចំពោះកម្រិតប្រើ ARV ប្រចាំថ្ងៃរបស់គាត់ ដើម្បីធានាគ្មានការអាក់ខានការប្រើ (ពោលគឺ ARVs អ្វីខ្លះ, ជំនួយប្រចាំថ្ងៃសម្រាប់ការប្រើថ្នាំ ARV/ការរំលឹក, ការរក្សាទុក ARV, តាមដានមើលផលរំខានរបស់ថ្នាំ, ការធ្វើដំណើរដោយមានការគ្រោងទុកជាមុន) ។<br>3) រំលឹកកាលបរិច្ឆេទណាត់ជួបនៅ ART ដើម្បីធានាថាយុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ អាចទទួលបានសេវាទាន់ពេលវេលា ។ ប្រើនាឡិការោទ៍ចល័ត ប្រសិនបើត្រូវការ ហើយកត់លេខទូរស័ព្ទរបស់បុគ្គលទំនាក់ទំនងក្នុងករណីមានគ្រោះអាសន្ន ។<br>4) ប្រាប់កូនរបស់គាត់ អំពីអ្នកណាដែលត្រូវស្វែងរកការគាំទ្រ ប្រសិនបើត្រូវការ ។<br>5) ធានាថា មានមធ្យោបាយធ្វើដំណើរ ឬរៀបចំមធ្យោបាយធ្វើដំណើរឱ្យទាន់ពេលវេលានិងមានសុវត្ថិភាព ។<br>6) ដឹងអំពីតម្រូវការនិងឯកសារចាំបាច់ដើម្បីចូលទៅកាន់គេហទំព័រ ART មនុស្សពេញវ័យ<br>7) ស្វែងយល់និងរៀបចំការគាំទ្រសម្រាប់យុវវ័យរបស់ពួកគេក្នុងអំឡុងពេលអន្តរកាល<br>8) ត្រួតពិនិត្យ និងតាមដានបន្តលើឥរិយាបថរបស់យុវវ័យចំពោះការប្រកាន់ខ្ជាប់តាមការព្យាបាល (ការលេបថ្នាំត្រឹមត្រូវ ទៀងទាត់ និងជាប់លាប់) ជាពិសេសក្នុងអំឡុងពេលចាប់ផ្តើមអន្តរកាល រហូតដល់ពួកគេអាចគ្រប់គ្រងខ្លួនឯងបានដោយជោគជ័យ ។ |
| អ្នកផ្តល់សេវាសុខភាព | 1) ត្រូវមានចំណេះដឹងនិងឆ្លើយតបទៅនឹងគ្រប់ដំណាក់នៃអន្តរកាល និងឧបករណ៍ត្រូវការ ។<br>2) ធានាថា យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ ត្រូវបានផ្តល់ជូននូវព័ត៌មានយ៉ាងច្បាស់នៅគ្រប់ដំណាក់នៃអន្តរកាល និងជួយពួកគេរៀបចំផែនការបុគ្គលដែលចាំបាច់សម្រាប់ការរក្សាទុក និងផែនការផ្ទេរចេញ ។<br>3) គ្រប់គ្រង រួមជាមួយអ្នកគ្រប់គ្រងករណី ឬដើរតួជាអ្នកគ្រប់គ្រងករណី ងរហូតដល់យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ អាចរៀបចំខ្លួនបានដោយរលូននៅក្នុងទីតាំងសម្រាប់មនុស្សពេញវ័យ ។ |

| ក្រុមសំខាន់ | តួនាទីនិងទំនួលខុសត្រូវសម្រាប់ការរៀបចំផ្ទេរចេញនៅទីតាំង PAC |
|---|---|
| | 4) ប្រើឧបករណ៍វាយតម្លៃនិងវាយតម្លៃ (មូលដ្ឋាន និងពេលបញ្ចប់) ដើម្បីកំណត់ចំណេះដឹង ឥរិយាបថ និងការប្រកាន់ខ្ជាប់តាមការព្យាបាល ARV មុននិងកំឡុងពេលដំណើរការផ្លាស់ប្តូរ។<br>5) វាយតម្លៃតម្រូវការរបស់ក្មេងជំទង់ និងអ្នកថែទាំរបស់ពួកគេបន្ទាប់មកជួយពួកគេ ក្នុងការបង្កើតផែនការអន្តរកាលសម្រាប់ យុវវ័យរស់នៅជាមួយមេរោគអេដស៍ ដោយផ្អែកលើតម្រូវការ។ សំគាល់៖ ផែនការត្រូវតែត្រូវបានរៀបចំតាមតម្រូវការរបស់បុគ្គលវ័យជំទង់ម្នាក់ៗ និងធនធានដូចជារាងកាយផ្លូវចិត្ត សង្គម វិញ្ញាណនិងសុខភាព និងសុខុមាលភាព<br>6) <u>**សម្រាប់ អ្នកជំងឺ ដែលបម្រុងនឹងផ្ទេរចេញ៖**</u><br>‣ ធ្វើជាអ្នកសម្រុះសម្រួលរវាងនិងក្នុងគ្លីនិកអេជីអឹមកុមារនិងមនុស្សពេញវ័យ។<br>‣ ត្រូវប្រាកដថាអាល់ហ៊ីវីទៅពិនិត្យកន្លែងចាក់ថ្នាំមនុស្សពេញវ័យដែលគាត់ចង់ទទួលបានសេវាកម្ម។<br>‣ ត្រូវប្រាកដថាគ្រូពេទ្យនឹងចេញវេជ្ជបញ្ជាថ្នាំ ARV ដូចគ្នាដើម្បីចៀសវាងការភ័ន្តច្រឡំរហូតដល់ពួកគេទទួលបានវេជ្ជបញ្ជាថ្នាំថ្មីនៅសេវាកម្ម ART សម្រាប់មនុស្សពេញវ័យថ្មី (យ៉ាងហោចណាស់ HCP គួរតែចេញវេជ្ជបញ្ជាថ្នាំ ARV ៣ ខែអ្នកជំងឺគួរតែចុះឈ្មោះនៅ ART មនុស្សពេញវ័យនៅពេលពួកគេមានថ្នាំដូច ឆាប់តាមដែលអាចធ្វើទៅបានឬយ៉ាងហោចណាស់ ១ ខែនៅក្នុងដៃ) ។<br>ខាងក្រោមនេះគឺជាភារកិច្ចសំខាន់ៗសម្រាប់អ្នកផ្តល់សេវាសុខភាព ដើម្បីរៀបចំខ្លួនទទួលអ្នកជំងឺដែលនឹងត្រូវផ្ទេរចេញក្នុងពេលឆាប់ៗ ៖<br>a) **គ្រូពេទ្យព្យាបាល Medical Doctors (MD)**<br>✓ រៀបចំលិខិតបញ្ជូននិងទម្រង់អ្នកជំងឺសង្ខេប៖ ធានាថាសំណុំបែបបទបំពេញនូវព័ត៌មានចាំបាច់ទាំងអស់រួមទាំងឈ្មោះរបស់ភីដស៍អ្នកផ្តល់ការទទួលខុសត្រូវលេខទំនាក់ទំនងនិងអាស័យដ្ឋាន<br>✓ អ្នកជំងឺត្រូវមានផ្ទុកមេរោគដែលមិនអាចរកឃើញ (ក្នុងរយៈពេល ២ ដងចុងក្រោយ-ពិនិត្យមើលការផ្ទុកមេរោគដោយផ្អែកលើតម្រូវការបច្ចេកទេស (លទ្ធផលនៃការផ្ទុកមេរោគគួរតែមានសុពលភាពក្នុងរយៈពេល ៦ ខែមុនពេលផ្ទេរចេញ)<br>✓ ធ្វើការជាមួយមន្ត្រីទិន្នន័យ/អ្នកគ្រប់គ្រងដើម្បីស្រង់ទិន្នន័យអ្នកជំងឺដើម្បីអាចកត់សម្គាល់ក្នុងទម្រង់អ្នកជំងឺសង្ខេប<br>✓ បញ្ជូនព័ត៌មានលំអិតរបស់អ្នកជំងឺទៅអង្គភាពចុះឈ្មោះ (គេហទំព័រផ្សេងទៀតបន្តបំពេញ ... ) |

| ក្រុមសំខាន់ | តួនាទីនិងទំនួលខុសត្រូវសម្រាប់ការរៀបចំផ្ទេរចេញនៅទីតាំង PAC |
|---|---|
| | ✓ ក្នុងករណីគ្មានការគាំទ្រពីerពុកម្តាយ / --ពុកម្តាយ - ការផ្លាស់ប្តូរក្រុមត្រូវបានលើកទឹកចិត្ត ( យ៉ាងហោចណាស់ក្មេងជំទង់ពីរនាក់ ) ទៅជាមួយគ្នាដើម្បីគាំទ្រគ្នាទៅវិញទៅមក<br>**b) គិលានុបដ្ឋាក/អ្នកផ្តល់ប្រឹក្សា**<br>✓ ជួយគ្រូពេទ្យ ដាក់លិខិតផ្ទេរ និងទម្រង់ព័ត៌មានអ្នកជំងឺសង្ខេបចូលក្នុងស្រោមសំបុត្រ ។<br>✓ ផ្តល់ប្រឹក្សាដល់អ្នកជំងឺ/អ្នកថែទាំ អំពីការរៀបចំខ្លួននៅពេលផ្ទេរទៅកាន់ទីតាំង ART សម្រាប់មនុស្សពេញវ័យ ។<br>✓ ជម្រាបព័ត៌មានដល់អ្នកជំងឺ និងអាណាព្យាបាលឱ្យនាំយកឯកសារពីរមកជាមួយពួកគេទៅគ្លីនិក ART សម្រាប់មនុស្សពេញវ័យ<br>✓ រៀបចំផែនការកិច្ចប្រជុំរវាងអ្នកផ្តល់សេវាសុខភាពថ្មី និងអ្នកជំងឺអន្តរកាលនៅមុនពេលការណាត់ជួបចុងក្រោយរបស់ពួកគេ ។<br>✓ ធ្វើការណាត់ជួបជាមួយគ្លីនិក ART សម្រាប់មនុស្សពេញវ័យ មុនពេលផ្ទេរ<br>**c) អង្គការក្រៅរដ្ឋាភិបាល/មិត្តភក្តិយុវវ័យ**<br>✓ សាកសួរយុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ អំពីការគាំទ្រដែលត្រូវការ<br>✓ ប្រាស្រ័យទាក់ទងជាមួយអង្គការក្រៅរដ្ឋាភិបាល/មិត្តភក្តិនៅគ្លីនិក ART សម្រាប់មនុស្សពេញវ័យ មុនពេលចុះទៅដល់/ផ្ទេរចេញ ។<br>✓ អមដំណើរយុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ទៅដល់ទីតាំង ART សម្រាប់មនុស្សពេញវ័យ ដើម្បីស្គាល់ពីទីតាំង, សេវាដែលមាន និងអ្នកផ្តល់សេវាសុខភាពដែលពួកគេអាចចុះឈ្មោះជាមួយដើម្បីទទួលសេវា ART ។<br>✓ ផ្តល់ការប្រឹក្សាជាបុគ្គលឬជាក្រុម ដើម្បីលើកទឹកចិត្តដល់យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ ដោះស្រាយក្តីបារម្ភរបស់ពួកគេ និងត្រៀមខ្លួនរួចរាល់សម្រាប់អន្តរកាលរបស់ពួកគេ ។ |

### 6.2.2. ការថែរក្សា

**តារាងទី 4:** ម៉ាទ្រីសតួនាទីនិងទំនួលខុសត្រូវសម្រាប់ការថែរក្សានៅទីតាំង PAC

| ក្រុមគោលដៅសំខាន់ | តួនាទីនិងទំនួលខុសត្រូវសម្រាប់ការថែរក្សានៅទីតាំង PAC |
|---|---|
| **យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍** (ALHIV) | 1) ចូលរួមវគ្គប្រឹក្សាជាមួយអ្នកផ្តល់ប្រឹក្សា ដើម្បីរៀបចំផែនការអន្តរកាលផ្ទាល់ខ្លួនរបស់ពួកគេ<br>2) រៀនធ្វើអ្វីៗដោយខ្លួនឯងដោយផ្អែកលើដំបូន្មានពីអ្នកផ្តល់សេវាសុខភាព (ពោលគឺ ថែទាំសុខភាពខ្លួនរបស់ពួកគេ, គ្រប់គ្រងថ្នាំ ARV) កំណត់ម៉ោងរោទិ៍ដើម្បីរំលឹក, ចំនួន ARV ដែលត្រូវលេប, អ្នករំលឹកប្រើថ្នាំ ARV, ការរក្សាទុក ARV, តាមដានផលរំខានថ្នាំ, វិធីយកថ្នាំរបស់ពួកគេតាមខ្លួនប្រសិនបើពួកគេទៅឆ្ងាយពីផ្ទះរបស់ពួកគេ ... )<br>3) ចូលរួមជាមួយក្រុមគាំទ្រប្រសិនបើមាន ដើម្បីរៀនសូត្រពីមិត្តភក្តិដទៃទៀត ដែលអាចធ្វើបានល្អជាងចំពោះការប្រកាន់ខ្ជាប់តាមការព្យាបាលរបស់ពួកគេ ឬស្តាប់អ្នកផ្តល់ប្រឹក្សាដោយយកចិត្តទុកដាក់ ឬសួរសំណួរប្រសិនបើពួកគេចង់ដឹងបន្ថែម ។<br>4) រៀនជំនាញដោះស្រាយបញ្ហា ដូចជា របៀបសម្គាល់ជំងឺរបស់ពួកគេ, អ្នកណាខ្លះដែលត្រូវពិគ្រោះ/ទាក់ទង នៅពេលគាត់ជួបប្រទះបញ្ហាប្រឈម និងស្វែងរកដំបូន្មានបន្ថែមពីអ្នកផ្តល់សេវាសុខភាព ប្រសិនបើចាំបាច់, អ្វីដែលត្រូវធ្វើដើម្បីដោះស្រាយបញ្ហារបស់ពួកគេ<br>5) ស្វែងយល់ពីតម្រូវការនិងឯកសារចាំបាច់ដើម្បីចូលទៅកាន់ទីតាំង ART មនុស្សពេញវ័យ ។<br>6) ការចូលទៅកាន់ទីតាំង ART ថ្មីសម្រាប់មនុស្សពេញវ័យ តាមកាលបរិច្ឆេទ/កាលវិភាគដែលបានណែនាំ<br>7) យល់ថា ពួកគេមិនចាំបាច់រង់ចាំរហូតដល់ពួកគេបញ្ចប់ថ្នាំ ARV ទាំងអស់នោះទេ ។ |
| **អាណាព្យាបាល** | 1) ផ្តល់ការគាំទ្រផ្នែកផ្លូវកាយ, ផ្លូវចិត្ត និងហិរញ្ញវត្ថុដល់យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ក្នុងពេលថែរក្សានៅកន្លែងដដែល - ពោលគឺ គឺលើកទឹកចិត្តឱ្យយុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ ស្រឡាញ់សុខភាពរបស់គាត់ និងទទួលខុសត្រូវចំពោះសុខភាពផ្ទាល់ខ្លួនគាត់ និងសុខភាពរបស់សហគមន៍ទាំងមូល ។ *សូមមើលការពង្រឹងការផ្តល់ប្រឹក្សាអំពីការគោរពតាមការព្យាបាល និងសម្ភារផ្តល់ប្រឹក្សាសម្រាប់អ្នកមានចំនួនមេរោគមិនអាចរាប់បាន = មិនអាចចម្លងបាន (the Undetected=Uninfected) សម្រាប់សារលម្អិតបន្ថែម ។*<br>2) ផ្តល់ការគាំទ្រដល់យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ ចំពោះកម្រិតប្រើ ARV ប្រចាំថ្ងៃរបស់គាត់ ដើម្បីធានាគ្មានការអាក់ខានការប្រើ (ពោលគឺ ARVs អ្វីខ្លះ, ជំនួយប្រចាំថ្ងៃ |

| ក្រុមគោលដៅសំខាន់ | តួនាទីនិងទំនួលខុសត្រូវសម្រាប់ការថែរក្សានៅទីតាំង PAC |
|---|---|
| | សម្រាប់ការប្រើថ្នាំ ARV/ការរំលឹក, ការរក្សាទុក ARV, តាមដានមើលផលរំខានរបស់ថ្នាំ, ការធ្វើដំណើរដោយមានការគ្រោងទុកជាមុន) ។<br>3) រំលឹកកាលបរិច្ឆេទណាត់ជួបនៅ ART ដើម្បីធានាថាយុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ អាចទទួលបានសេវាទាន់ពេលវេលា ។ ប្រើនាឡិការោទិ៍ចល័ត ប្រសិនបើត្រូវការ ហើយកត់លេខទូរស័ព្ទរបស់បុគ្គលទំនាក់ទំនងក្នុងករណីមានគ្រោះអាសន្ន ។<br>4) ប្រាប់កូនរបស់គាត់ អំពីអ្នកណាដែលត្រូវស្វែងរកការគាំទ្រ ប្រសិនបើត្រូវការ ។<br>5) ធានាថា មានមធ្យោបាយធ្វើដំណើរ ឬរៀបចំមធ្យោបាយធ្វើដំណើរឱ្យទាន់ពេលវេលានិងមានសុវត្ថិភាព ។<br>6) ត្រួតពិនិត្យ និងតាមដានបន្តលើឥរិយាបថរបស់យុវវ័យចំពោះការប្រកាន់ខ្ជាប់តាមការព្យាបាល ជាពិសេសក្នុងអំឡុងពេលចាប់ផ្តើមអន្តរកាល រហូតដល់ពួកគេអាចគ្រប់គ្រងខ្លួនឯងបានដោយជោគជ័យ ។<br>7) ដឹងអំពីតម្រូវការនិងឯកសារចាំបាច់ដើម្បីចូលទៅទីតាំង ART សម្រាប់មនុស្សពេញវ័យ<br>8) ស្វែងយល់និងរៀបចំការគាំទ្រសម្រាប់យុវវ័យរបស់ពួកគេក្នុងអំឡុងពេលអន្តរកាល |
| **អ្នកផ្តល់សេវាសុខភាព** | 1) ត្រូវមានចំណេះដឹងនិងឆ្លើយតបទៅនឹងគ្រប់ជំហាននៃអន្តរកាល និងឧបករណ៍ដែលត្រូវការ ។<br>2) ធានាថា យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ ត្រូវបានផ្តល់ជូននូវព័ត៌មានយ៉ាងច្បាស់នៅគ្រប់ជំហាននៃអន្តរកាល និងជួយពួកគេរៀបចំផែនការបុគ្គលដែលចាំបាច់សម្រាប់ការរក្សាទុក និងផែនការផ្ទេរចេញ ។<br>3) គ្រប់គ្រង រួមជាមួយអ្នកគ្រប់គ្រងករណី ឬដើរតួជាអ្នកគ្រប់គ្រងករណី ងរហូតដល់យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ អាចរៀបចំខ្លួនបានដោយរលូននៅក្នុងទីតាំងសម្រាប់មនុស្សពេញវ័យ ។<br>4) ប្រើឧបករណ៍ប៉ាន់ប្រមាណនិងវាយតម្លៃ (មូលដ្ឋាននិងចុងបញ្ចប់) ដើម្បីកំណត់ពីចំណេះដឹង ឥរិយាបថ និងការប្រកាន់ខ្ជាប់តាមការព្យាបាលដោយ ARV មុនពេលនិងក្នុងអំឡុងពេលដំណើរការអន្តរកាល<br>5) ប៉ាន់ប្រមាណតម្រូវការរបស់យុវវ័យ និងអ្នកថែទាំរបស់ពួកគេ បន្ទាប់មក ជួយពួកគេរៀបចំបង្កើតផែនការអន្តរកាលសម្រាប់យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ ដោយផ្អែកលើតម្រូវការ ។ សម្គាល់៖ ផែនការនេះត្រូវតែរៀបចំឡើងផ្អែកតាមសមត្ថភាពរបស់បុគ្គលជាយុវវ័យម្នាក់ៗ និងធនធានដែលមាន ដូចជា ផ្លូវកាយ ផ្លូវចិត្ត សង្គម ស្មារតី និងសុខភាព និងសុខុមាលភាព ។ |

## 6.3. ក្រោយអន្តរកាល

### *6.3.1. ការផ្ទេរចេញ*

**តារាងទី 5:** ម៉ាទ្រីសតួនាទីនិងទំនួលខុសត្រូវរបស់អ្នកផ្តល់សេវាសុខភាព យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ និងអាណាព្យាបាលនៅឯទីតាំង ART សម្រាប់មនុស្សពេញវ័យ

| ក្រុមគន្លឹះ | ម៉ាទ្រីសតួនាទីនិងទំនួលខុសត្រូវរបស់អ្នកផ្តល់សេវា យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ និងអាណាព្យាបាលនៅឯទីតាំង ART សម្រាប់មនុស្សពេញវ័យ |
|---|---|
| យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ (ALHIV) | 1) ធ្វើតាមអនុសាសន៍/ដំបូន្មានពីអ្នកផ្តល់សេវា ART សម្រាប់មនុស្សពេញវ័យ។<br>2) រៀនគ្រប់គ្រងកាលវិភាគ/ការធ្វើដំណើររបស់ពួកគេដើម្បីទៅទទួលបានសេវា ART នៅទីតាំង ART សម្រាប់មនុស្សពេញវ័យ;<br>3) ផ្តល់ព័ត៌មាន/ពិគ្រោះយោបល់ជាមួយអាណាព្យាបាល/ មិត្តភក្តិ/ អ្នកផ្តល់សេវាថែទាំសុខភាពដើម្បីផ្តល់ការគាំទ្រ ប្រសិនបើមានបញ្ហាឬការផ្លាស់ប្តូរណាមួយ<br>4) រៀនធ្វើការសម្របខ្លួនទៅនឹងបរិយាកាសថ្មីនៃគ្លីនិក ART សម្រាប់មនុស្សពេញវ័យ;<br>5) ត្រួតពិនិត្យនិងតាមដានសុខភាពផ្ទាល់ខ្លួន និងការប្រកាន់ខ្ជាប់តាមការព្យាបាល បន្ទាប់ពីការផ្ទេរចេញ |
| អាណាព្យាបាល | 1) ផ្តល់ការគាំទ្រផ្នែកផ្លូវកាយ, ផ្លូវចិត្ត និងហិរញ្ញវត្ថុដល់យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍បន្ទាប់ផ្ទេរចេញ (ពោលគឺ គឺលើកទឹកចិត្តឱ្យយុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ ស្រឡាញ់សុខភាពរបស់គាត់ និងទទួលខុសត្រូវចំពោះសុខភាពផ្ទាល់ខ្លួនគាត់ និងសុខភាពរបស់សហគមន៍ទាំងមូល ។ *សូមមើលការពង្រឹងការផ្តល់ប្រឹក្សាអំពីការគោរពតាមការព្យាបាល និងសម្ភារផ្តល់ប្រឹក្សាសម្រាប់ អ្នកមានចំនួនមេរោគមិនអាចរាប់បាន = មិនអាចចម្លងបាន (the Undetected=Uninfected) សម្រាប់សារលម្អិតបន្ថែម ។*<br>2) ត្រួតពិនិត្យ និងតាមដានបន្តមើលឥរិយាបថរបស់គាត់ ចំពោះការប្រកាន់ខ្ជាប់តាមការព្យាបាល ជាពិសេសក្រោយពេលផ្ទេរចេញ រហូតដល់ពួកគេអាចគ្រប់គ្រងខ្លួនឯងបានដោយជោគជ័យ ។<br>3) ពិគ្រោះយោបល់/ស្វែងរកការគាំទ្រជូនអ្នកផ្តល់សេវា នៅពេលមានបញ្ហាប្រឈមជាមួយយុវវ័យអន្តរកាលក្នុងពេលថ្មីៗរបស់ពួកគេ ។ |
| អ្នកផ្តល់សេវាសុខភាព | ○ **វេជ្ជបណ្ឌិត/គិលានុបដ្ឋាក/អ្នកផ្តល់ប្រឹក្សា**<br>▸ ផ្តល់អាទិភាពដល់កាលវិភាគសម្រាប់អ្នកជំងឺអន្តរកាលថ្មី - ធ្វើការណាត់ជួបពីរ ឬ បីជាប់ដោយឡែកពីគ្នាសម្រាប់ទទួលថ្នាំ ARV របស់ពួកគេ ។ |

| | |
|---|---|
| | ▸ ត្រួតពិនិត្យ/តាមដានបន្តមើលសុខភាពរបស់យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ សុខភាពរបស់អ្នកជំងឺអន្តរកាលថ្មី និងផ្តល់ការគាំទ្រដែលចាំបាច់ផ្សេងទៀត ។<br>▸ លើកកម្ពស់បរិយាកាសសេវាមេត្រីភាពយុវវ័យ តាមរយៈវិធីប្រាស្រ័យទាក់ទង, ការវិនិច្ឆ័យ, ការបង្កើតទំនាក់ទំនង-មានអារម្មណ៍កក់ក្តៅ និងមានទំនុកចិត្តក្នុងការចែករំលែកព័ត៌មានផ្ទាល់ខ្លួនរបស់ពួកគេ, រឿងរ៉ាវរបស់ពួកគេ ។<br>○ **អង្គការមិនមែនរដ្ឋាភិបាល/បណ្តាញមិត្តភក្តិយុវវ័យ**<br>▸ ជម្រាបដល់យុវវ័យដែលបានផ្ទេររួចហើយ ឱ្យស្វែងរកការគាំទ្រនៅទីតាំង PAC ប្រសិនបើពួកគេត្រូវការ ដោយផ្តល់លេខទំនាក់ទំនងដល់ពួកគេ ។<br>▸ លើកកម្ពស់បណ្តាញយុវវ័យ ដើម្បីអនុវត្តតាមផែនការតាមដាន (AHC - មិត្តភក្តិធ្វើការតាមដានបន្តយ៉ាងតិច ២ ដង ក្រោយពេលអន្តរកាលទៅកាន់គ្លីនិក ART សម្រាប់មនុស្សពេញវ័យ ។<br>▸ ក្នុងករណីមានភាពស្មុគស្មាញ (ពោលគឺ អំពើហិង្សាក្នុងគ្រួសារ, កង្វះការគាំទ្រនៅផ្ទះ ឬគ្រួសារ)៖ អ្នកប្រឹក្សា/មិត្តភក្តិយុវវ័យ បន្តការតាមដានជាមួយយុវវ័យដែលបានផ្ទេរ ប្រសិនបើមានករណី បោះបង់ការព្យាបាល ៣-៦ ខែ។ |

### *6.3.2. ការថែរក្សា*

**តារាងទី 6:** ម៉ាទ្រីសតួនាទីនិងទំនួលខុសត្រូវរបស់អ្នកផ្តល់សេវាសុខភាព យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ និងអណាព្យាបាលនៅទីតាំង PAC

| ក្រុមគន្លឹះ | ម៉ាទ្រីសតួនាទីនិងទំនួលខុសត្រូវរបស់អ្នកផ្តល់សេវាសុខភាព យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ និងអាណាព្យាបាល នៅទីតាំង PAC |
|---|---|
| **យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍** | 1) អនុវត្តតាមអនុសាសន៍/ដំបូន្មានពីអ្នកផ្តល់ការព្យាបាល ART សម្រាប់មនុស្សពេញវ័យ<br>2) រៀនត្រួតពិនិត្យនិងតាមដានបន្តមើលសុខភាពផ្ទាល់ខ្លួន និងការប្រកាន់ខ្ជាប់តាមការព្យាបាល<br>3) ជម្រាប/ពិគ្រោះយោបល់ជាមួយអាណាព្យាបាល/មិត្តភក្តិ/អ្នកផ្តល់សេវាថែទាំសុខភាពដើម្បីទទួលបានការគាំទ្រ ប្រសិនបើមានបញ្ហាប្រឈមណាមួយ |
| **អាណាព្យាបាល** | 1) បន្តផ្តល់ការគាំទ្រផ្នែកផ្លូវកាយ ផ្លូវចិត្ត និងហិរញ្ញវត្ថុដល់យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍នៅទីតាំង PAC នៅពេលចាំបាច់<br>2) ស្វែងយល់និងរៀបចំការគាំទ្រដល់យុវវ័យក្នុងអំឡុងពេលអន្តរកាល |

| | |
|---|---|
| | 3) ត្រួតពិនិត្យនិងតាមដានមើលឥរិយាបថរបស់យុវវ័យ ចំពោះការប្រកាន់ខ្ជាប់តាមការព្យាបាល ជាពិសេសបន្ទាប់ពីការផ្ទេរចេញ និងធានាថា ពួកគេអាចគ្រប់គ្រងខ្លួនឯងបានដោយជោគជ័យ។ |
| **អ្នកផ្តល់សេវាថែទាំសុខភាព (HCP)** | ○ **វេជ្ជបណ្ឌិត/គិលានុបដ្ឋាក/អ្នកផ្តល់ប្រឹក្សា**<br>‣ តាមដានបន្តមើលសុខភាពរបស់យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ និងផ្តល់ការគាំទ្រដែលចាំបាច់ផ្សេងទៀត ។<br>‣ លើកកម្ពស់បរិយាកាសមេត្រីភាព ចំពោះយុវវ័យ តាមរយៈវិធីប្រាស្រ័យទាក់ទង, ការវិនិច្ឆ័យ, ការបង្កើតទំនាក់ទំនង-មានអារម្មណ៍កក់ក្តៅ និងមានទំនុកចិត្តក្នុងការចែករំលែកព័ត៌មានផ្ទាល់ខ្លួនរបស់ពួកគេ, រឿងរ៉ាវរបស់ពួកគេ ។<br>○ **អង្គការមិនមែនរដ្ឋាភិបាល/បណ្តាញមិត្តភក្តិយុវវ័យ**<br>‣ លើកកម្ពស់បណ្តាញយុវវ័យ ដើម្បីអនុវត្តតាមផែនការតាមដាន (AHC - មិត្តភក្តិធ្វើការតាមដានបន្តយ៉ាងតិច ២ ដង ក្រោយពេលអន្តរកាលទៅកាន់គ្លីនិក ART សម្រាប់មនុស្សពេញវ័យ ។ |

# 7. ការត្រួតពិនិត្យតាមដាន និងការរាយការណ៍

## 7.1. សូចនាករត្រួតពិនិត្យតាមដាន និងការរាយការណ៍

ទីតាំងនីមួយៗ គួរកត់ត្រាសូចនាករស្នូលដែលទាក់ទងនឹងអន្តរកាល ដោយផ្អែកលើកំណត់ត្រា អ្នកជំងឺម្នាក់ៗ ។ ជារៀងរាល់ត្រីមាស អ្នកផ្តល់ប្រឹក្សាគួរតែបញ្ជូនកំណត់ត្រាសង្ខេប (និងកំណត់ត្រាបុគ្គល) ទៅមន្ត្រីទិន្នន័យ បន្ទាប់ពីរយៈពេលរាយការណ៍របស់ ART, *សូមមើលសេចក្តីបន្ថែមទី ៣ ។*

## 7.2. ដំណើរការគ្រប់គ្រងការត្រួតពិនិត្យតាមដាន និងការគ្រប់គ្រងការបោះបង់សេវា

ដើម្បីត្រួតពិនិត្យតាមដាននិងសម្របសម្រួលអន្តរកាលប្រកបដោយជោគជ័យ សកម្មភាពទាំងឡាយដូចខាងក្រោមនេះ ត្រូវបានស្នើឡើង ៖

- រៀបចំកិច្ចប្រជុំប្រចាំត្រីមាសរវាងគ្លីនិក ART កុមារនិងមនុស្សពេញវ័យ នៅក្នុងតំបន់ ឬទូទាំងប្រទេស ដើម្បីតាមដានទិន្នន័យបញ្ជូន និង LTFU
- កែលម្អការសម្របសម្រួលរវាងគ្លីនិក ART កុមារនិងមនុស្សពេញវ័យ ART នៅក្នុងតំបន់

- ប្រសិនបើគ្មានក្រុមគាំទ្រមិត្តភក្តិ/អង្គការក្រៅរដ្ឋាភិបាលៈ ការហៅទូរស័ព្ទតាមដានបន្តមិនអាចធ្វើទៅបាន និង
- ទាក់ទងនឹងទម្រង់របាយការណ៍ អ្នកផ្តល់សេវាសុខភាពប្រើទម្រង់របាយការណ៍អំពីគំរូនៅក្នុង និយាមបែបបទស្តីពី ការតាមរកអ្នកជំងឺត្រលប់មកទទួលសេវាថែទាំព្យាបាលវិញ ( Re-engagement SOP ) ។

# ឧសម្ព័ន្ធ

## ឧបករណ៍ត្រៀមអន្តរកាល

**ឧសម្ព័ន្ធទី 1:** បញ្ជីផ្ទៀងផ្ទាត់សម្រាប់ការវាយតម្លៃបឋមសម្រាប់ត្រៀមអន្តរកាល (សម្រាប់អ្នកផ្តល់សេវាសុខភាព)

| **ព័ត៌មានអំពីអ្នកជំងឺ** | |
|---|---|
| លេខសម្គាល់គ្លីនិកអ្នកជំងឺ៖................................<br>ភេទ៖ ..........................................................<br>ឈ្មោះអ្នកផ្តល់ប្រឹក្សា៖........................................ | លេខសម្គាល់អ្នកជំងឺ (លេខ ART)៖ ......................<br>អាយុ៖ ..........................................................<br>ថ្ងៃខែឆ្នាំ៖........................................................ |

| លរ | បរិយាយ | Yes | No | កំណត់សម្គាល់ |
|---|---|---|---|---|
| A. | **ពិនិត្យលក្ខណៈវិនិច្ឆ័យនៃភាពសមស្រប** | | | |
| I | **លក្ខណៈវិនិច្ឆ័យ អាយុ** | | | |
| 1.1 | អាយុសមស្របសម្រាប់ការវាយតម្លៃត្រៀមអន្តរកាល៖ | | | |
| | ▸ ≥ ១០ឆ្នាំ៖ ដាប់ ការវាយតម្លៃត្រៀមអន្តរកាល | | | |
| | ▸ ១១ – ១៤ ឆ្នាំ៖ យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ នឹងស្ថិតក្នុងដំណាក់កាលអន្តរកាល (ត្រៀមខ្លួនសម្រាប់ផ្ទេរចេញ ឬរក្សានៅក្នុងសេវាដដែល)។ | | | |
| | ▸ ≥ ១៥ ឆ្នាំ៖ យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ នឹងប្តូរទៅក្រោយអន្តរកាល (ផ្ទេរចេញ ឬស្ថិតនៅដដែល) | | | |
| II | **លទ្ធផលតេស្តរាប់បន្ទុកមេរោគ** | | | |
| 2.1 | ការបង្ក្រាបបន្ទុកមេរោគ៖ លទ្ធផលពីរចុងក្រោយដែលមេរោគបានបង្ក្រាប (NCHADS) និងលទ្ធផលថ្មីបំផុតក្នុងរយៈពេល ៦ខែ | | | |
| 2.2 | លទ្ធផលតេស្តរាប់បន្ទុកមេរោគ លើកទី១៖<br>ថ្ងៃខែឆ្នាំធ្វើតេស្តរាប់បន្ទុកមេរោគ ............................................<br>លទ្ធផលតេស្តរាប់បន្ទុកមេរោគ ............................................ | | | |
| 2.3 | លទ្ធផលតេស្តរាប់បន្ទុកមេរោគ លើកទី២៖ | | | |

| លរ | បរិយាយ | Yes | No | កំណត់សម្គាល់ |
|---|---|---|---|---|
| | ថ្ងៃខែឆ្នាំធ្វើតេស្តរាប់បន្ទុកមេរោគ …………………………………….. <br> លទ្ធផលតេស្តរាប់បន្ទុកមេរោគ ……………………………………. | | | |
| III | រូបមន្តព្យាបាល ARV | | | |
| 3.1 | ‣ រូបមន្តជួរទីមួយ (បច្ចុប្បន្ន) <br> រូបមន្ត ARV………………………………………. | | | |
| | ‣ រូបមន្ត ARV………………………………………. | | | |
| | ‣ រូបមន្ត ARV………………………………………. | | | |
| IV | តើយុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ បានទទួលការបង្ហាញពីស្ថានភាពមេរោគអេដស៍ឬនៅ? | | | |
| 4.1 | A. យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ និងគ្រួសារ មិនទាន់បានបង្ហាញនៅឡើយទេ | | | |
| 4.2 | B. យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ និងគ្រួសារ បានបង្ហាញរួចហើយ | | | |
| 4.3 | C. យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ និងគ្រួសារ មានបំណងបង្ហាញ | | | |
| 4.4 | D. ការបង្ហាញស្ថានភាពមេរោគអេដស៍ដោយផ្នែក ដោយអ្នកផ្តល់សេវាសុខភាព (Semi-disclosure by HCP) | | | |

**សម្គាល់៖** *កុមារអាយុ >6 ឆ្នាំ(A, B, C); D គឺសម្រាប់កុមារអាយុ <6 ឆ្នាំ; * កុមារដែលត្រូវបានជម្រាបប្រាប់អំពីការឆ្លងរោគ ដែលក្នុងនោះកុមារត្រូវទទួលការព្យាបាលពេញមួយជីវិត និងតាមដានចំនួនបន្ទុកមេរោគមួយជីវិត។*

**សន្និដ្ឋានទូទៅសម្រាប់ជំហានបន្ទាប់៖**

**ដោយអ្នកផ្តល់ប្រឹក្សា (ឈ្មោះ និង ថ្ងៃខែឆ្នាំ)៖**

______________________________________________

______________________________________________

______________________________________________

**ដោយគ្រូពេទ្យ (ឈ្មោះ និង ថ្ងៃខែឆ្នាំ)៖** ______________________________

______________________________________________

## ឧបសម្ព័ន្ធទី ២៖ ការវាយតម្លៃសុខុមាលភាព និងចំណេះដឹងមូលដ្ឋានរបស់យុវវ័យ

| ព័ត៌មានអ្នកជំងឺ | |
|---|---|
| លេខសម្គាល់គ្លីនិកអ្នកជំងឺ៖ ............................ | លេខសម្គាល់អ្នកជំងឺ (លេខ ART)៖ ................ |
| ភេទ៖.................................................... | អាយុ៖................................................ |
| ឈ្មោះអ្នកផ្តល់ប្រឹក្សា៖ .................................. | ថ្ងៃខែឆ្នាំ៖............................................. |

| ផ្នែកទី I: ការវាយតម្លៃសុខុមាលភាពយុវវ័យ | | | |
|---|---|---|---|
| **បរិយាយ/សេចក្តីថ្លែងការណ៍** | **អត់សោះ** | **ជួនកាល** | **គ្រប់ពេល** |
| **1.1. អាហារូបត្ថម្ភ** | | | |
| ខ្ញុំញ៉ាំអាហារយ៉ាងតិចពីរពេលក្នុងមួយថ្ងៃ ដោយក្នុងនោះអាហារមួយពេលមានសាច់និងបន្លែខ្លះ | | | |
| ខ្ញុំមានអាហារតិចជាងអ្នកដទៃទៀតនៅក្នុងគ្រួសារខ្ញុំ | | | |
| **1.2. ការអប់រំ** | | | |
| ខ្ញុំទៅសាលារៀនជាទៀងទាត់ | | | |
| ខ្ញុំមានសម្ភារដែលខ្ញុំត្រូវការដើម្បីធ្វើកិច្ចការសាលារបស់ខ្ញុំ | | | |
| ខ្ញុំទៅរៀន មានអ្នកគាំទ្រ ជួយខ្ញុំទៅសាលារៀន | | | |
| ខ្ញុំចូលចិត្តសាលារៀន | | | |
| **1.3 ស្ថានភាពហិរញ្ញវត្ថុ** | | | |
| គ្រួសាររបស់ខ្ញុំមានលុយគ្រប់គ្រាន់ដើម្បីទិញរបស់ដែលខ្ញុំត្រូវការ | | | |
| គ្រួសាររបស់ខ្ញុំអាចមានលទ្ធភាពធ្វើដំណើរទៅជួបគ្រូពេទ្យតាមការណាត់ជួប | | | |
| **1.4 សុខភាពផ្លូវកាយនិងសុខុមាលភាព** | | | |
| ខ្ញុំមានអារម្មណ៍ថាមានកម្លាំងនិងមានសុខភាពល្អ | | | |
| ខ្ញុំព្រួយបារម្ភអំពីសុខភាពរបស់ខ្ញុំ | | | |
| ខ្ញុំកំពុងតែលូតលាស់ ដូចកុមារផ្សេងទៀតដែលមានអាយុដូចខ្ញុំដែរ | | | |
| ខ្ញុំមានអារម្មណ៍ថា ខ្ញុំមានឱកាសឬមានសំណាងដូចកុមារដទៃទៀតដែរ | | | |
| **1.5 សុខភាពផ្លូវចិត្ត និងទំនាក់ទំនងក្នុងសង្គម** | | | |

| | | | |
|---|---|---|---|
| ខ្ញុំសប្បាយចិត្តដូចកុមារដទៃទៀតអាយុស្មើខ្ញុំដែរ | | | |
| មានមនុស្សធំនៅផ្ទះ (ឧទា. ឪពុកឬម្តាយ/អាណាព្យាបាល) ឬនៅក្នុងសហគមន៍ (ឧទា. អ្នកជិតខាង) ដែលខ្ញុំជឿទុកចិត្ត និងគាំទ្រខ្ញុំផ្នែកផ្លូវអារម្មណ៍ | | | |
| ខ្ញុំមានមិត្តយ៉ាងតិចម្នាក់ ដែលខ្ញុំអាចចែករំលែករឿងសម្ងាត់ជាមួយ និងដែលខ្ញុំទុកចិត្ត | | | |
| *សម្គាល់៖ អ្នកផ្តល់សេវា គួរប្រើឧបករណ៍ K10 (ជញ្ជីងវាស់សម្ពាធផ្លូវចិត្តខេស្លឺរ Kessler Psychological Distress Scale) សូមមើលឧបសម្ព័ន្ធទី ៥ ដើម្បីវាយតម្លៃលក្ខខណ្ឌសុខភាពផ្លូវចិត្តរបស់អ្នកជំងឺ។* | | | |
| **1.6 សម្ពាធ, គ្រោះថ្នាក់ និងសុខភាពផ្លូវភេទ** | | | |
| ខ្ញុំយល់អំពីការផ្លាស់ប្តូរទាំងឡាយដែលរាងកាយខ្ញុំឆ្លងកាត់ក្នុងពេលពេញវ័យ (យុវវ័យ) | | | |
| ខ្ញុំដឹងពីវិធីដែលក្មេងស្រីអាចមានផ្ទៃពោះ និងដឹងពីរបៀបការពារមិនឱ្យមានផ្ទៃពោះ (ការពន្យារកំណើត) | | | |
| ខ្ញុំដឹងពីរបៀបបង្ការការចម្លងមេរោគអេដស៍ | | | |
| ខ្ញុំមានអារម្មណ៍ថា ខ្ញុំអាចធ្វើការសម្រេចចិត្តខ្លួនឯងអំពីអ្វីដែលសំខាន់សម្រាប់ខ្ញុំ | | | |
| ខ្ញុំមានមនុស្សដែលសុំស្រឡាញ់ខ្ញុំ និងចង់រៀបការជាមួយខ្ញុំ ដែលធ្វើឱ្យខ្ញុំពិបាកឆ្លើយចំពោះពួកគេ។ | | | |
| រាងកាយខ្ញុំជួនកាលត្រូវគេរំលោភបំពាន ឧទាហរណ៍ ជួនកាល ខ្ញុំទទួលរងត្រូវគេវាយជំខ្លាំងៗ ឬប៉ះខ្លាំងៗ។ | | | |
| ខ្ញុំធ្វើអ្វីដែលអាចធ្វើឱ្យខ្ញុំប្រឈមនឹងការឆ្លងកាមរោគឬមានផ្ទៃពោះ (ក្មេងស្រី)/ឬធ្វើឱ្យនរណាម្នាក់មានផ្ទៃពោះ (ក្មេងប្រុស) | | | |

**ការសន្និដ្ឋានទូទៅសម្រាប់ជំហានបន្ទាប់៖**

**ដោយអ្នកផ្តល់ប្រឹក្សា (ឈ្មោះ និងថ្ងៃខែឆ្នាំ):** ____________________

____________________

____________________

**ដោយគ្រូពេទ្យ (ឈ្មោះនិងថ្ងៃខែឆ្នាំ):** ____________________

____________________

| ផ្នែកទី II. ការវាយតម្លៃចំណេះដឹងជាមូលដ្ឋាន | | | | | |
|---|---|---|---|---|---|
| ថ្ងៃខែឆ្នាំវាយតម្លៃ | ថ្ងៃខែឆ្នាំ (មុន) ……………… …… | | ថ្ងៃខែឆ្នាំ (ក្រោយ) ……………… …… | | |
| **បរិយាយ/សេចក្តីថ្លែងការណ៍**<br>*(ការដាក់ពិន្ទុ៖ ចម្លើយ "Yes"=1, "No" = 0)* | Yes | No | Yes | No | **កំណត់សម្គាល់** |
| **ការអប់រំកម្រិតទី I** | | | | | |
| a.1. ចំណេះដឹងអំពីមេរោគអេដស៍ជាមូលដ្ឋាន | | | | | |
| 1) តើយុវវ័យដែលរស់នៅជាមួយមេរោគអេដស៍យល់ថា មេរោគអេដស៍គឺជាអ្វីឬទេ? | | | | | |
| 2) តើអ្នកយុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ យល់ពីវិធីដែលមេរោគអេដស៍រីករាលដាលពីមនុស្សម្នាក់ទៅម្នាក់ទៀត ឬទេ? | | | | | |
| 3) តើយុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ដឹងពីរបៀបនៃបង្ការការចម្លងមេរោគអេដស៍ពីមនុស្សម្នាក់ទៅម្នាក់ទៀត ឬទេ? | | | | | |
| 4) តើយុវវ័យដែលរស់នៅជាមួយមេរោគអេដស៍យល់ពីរបៀបដែលមេរោគអេដស៍វាយប្រហារទៅលើកោសិកា CD4 ដែរ ឬទេ? | | | | | |
| 5) តើយុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ យល់ពីតេស្តមន្ទីរពិសោធន៍ដែលគាត់បានទទួលឬទេ? | | | | | |
| 6) តើយុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ ដឹងតើអ្វីជាការធ្វើតេស្តរាប់បន្ទុកមេរោគ ឬទេ? | | | | | |

| | | | | | |
|---|---|---|---|---|---|
| 7) តើយុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ដឹងថា តើការព្យាបាលដោយ ARV គឺជាអ្វី ឬទេ? | | | | | |
| 8) តើយុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ដឹងពី ប្រភេទថ្នាំដែលគាត់បាន ឬ កំពុងប្រើឬទេ? | | | | | |
| **a.2. អនាម័យផ្ទាល់ខ្លួន** | | | | | |
| 9) តើយុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ ធ្វើលំហាត់ប្រាណជាទៀងទាត់ឬទេ? បើធ្វើ តើប៉ុន្មានដងក្នុងមួយសប្តាហ៍? (៣ ដង/ម៉ោង ក្នុងមួយសប្តាហ៍ គឺ yes, < 3 គឺ no) | | | | | |
| 10) តើយុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ ដុសធ្មេញរបស់គាត់ជាទៀងទាត់ឬទេ? បើដុះ តើប៉ុន្មានដងក្នុងមួយសប្តាហ៍? (យ៉ាងតិច រៀងរាល់ថ្ងៃ "yes", មិនរាល់ថ្ងៃ គឺ "no") | | | | | |
| **a.3 ការរៀបចំ បង្ហាញស្ថានភាពមេរោគអេដស៍** | | | | | |
| 11) តើយុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ ដឹងហេតុអ្វីបានជាគាត់ប្រើថ្នាំរាល់ថ្ងៃដែរឬទេ? | | | | | |
| 12) តើយុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ ដឹងថាមានផលវិបាកផ្នែកសុខភាពឬទេ ប្រសិនបើគាត់មិនលេបថ្នាំតាមការណែនាំរបស់គ្រូពេទ្យ? | | | | | |
| 13) តើឪពុកម្តាយឬអាណាព្យាបាលរបស់យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ បានប្រាប់គាត់អំពីមូលហេតុដែលពួកគេត្រូវលេបថ្នាំពេញមួយជីវិតឬទេ? | | | | | |
| 14) តើយុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ស្គាល់មន្ទីរពេទ្យដែលគាត់ទៅបើកថ្នាំរបស់គាត់ជាទៀងទាត់ឬទេ? | | | | | |
| 15) តើយុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ មិនចូលចិត្តថ្នាំដែលគាត់លេបរាល់ថ្ងៃឬទេ? | | | | | |
| **ពិន្ទុសរុប a.1 + a.2 + a.3** | | | | | |

| | | | | | |
|---|---|---|---|---|---|
| (សម្រាប់ការវាយតម្លៃក្រោយអន្តរកាល៖ ប្រសិនបើពិន្ទុ 1-6 = អន់; 7-11 = មធ្យម; >11 = អាចទទួលយកបាន។ ចាប់ពីពិន្ទុ >9, អាចប្តូរទៅកម្រិតអប់រំទី II) | | | | | |
| | | | | | |
| ថ្ងៃខែឆ្នាំ វាយតម្លៃ | ថ្ងៃខែឆ្នាំ (មុន) ………………… | | ថ្ងៃខែឆ្នាំ (ក្រោយ) ………………… | | |
| បរិយាយ/សេចក្តីថ្លែងការណ៍<br>*(Scoring: answer "Yes"=1, "No" = 0)* | Yes | No | Yes | No | កំណត់សម្គាល់ |
| កម្រិតអប់រំទី II | | | | | |
| b.1. ជំងឺឱកាសនិយម (OIs)- តើយុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ ឆ្លើយបានត្រឹមត្រូវឬទេ៖ | | | | | |
| 1) តើជំងឺឱកាសនិយមគឺជាអ្វី? | | | | | |
| 2) ចូរផ្តល់ឧទាហរណ៍ខ្លះៗនៃជំងឺឱកាសនិយម? | | | | | |
| 3) តើមនុស្សឆ្លងជំងឺឱកាសនិយមដោយវិធីណា? | | | | | |
| 4) តើជំងឺឱកាសនិយមអាចបង្កផលប៉ះពាល់អ្វីខ្លះដល់មនុស្ស? | | | | | |
| 5) តើមនុស្សប្រភេទណាខ្លះដែលអាចឆ្លងជំងឺឱកាសនិយមច្រើនជាងគេ? | | | | | |
| 6) តើអ្នកអាចបង្ការការចម្លងជំងឺឱកាសនិយមដោយវិធីណា? | | | | | |
| b.2 ការបង្ហាញស្ថានភាពមេរោគអេដស៍ - តើយុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ ឆ្លើយបានត្រឹមត្រូវឬទេ៖ | | | | | |
| 7) តើអ្នកដឹងទេថា អ្នកកំពុងទទួលការព្យាបាល ART/មេរោគអេដស៍? | | | | | |
| 8) តើអ្នកគិតថា អ្នកអាចប្រាប់មិត្តភក្តិរបស់អ្នកថា អ្នកមានមេរោគអេដស៍ដែរឬទេ? | | | | | |

| | | | | | |
|---|---|---|---|---|---|
| 9) តើយុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ លាក់ស្ថាន-ភាពមេរោគអេដស៍ ពីគេគ្រប់គ្នាដែរឬទេ? | | | | | |
| 10) តើអ្នកមានអារម្មណ៍អាក់អន់ចិត្តឬទេ ប្រសិនបើមិត្តភក្តិរបស់អ្នកដឹងស្ថានភាពមេរោគអេដស៍របស់អ្នក? | | | | | |
| 11) តើអ្នកដឹងថាត្រូវធ្វើអ្វីទេ ប្រសិនបើអ្នកត្រូវមិត្តភក្តិរបស់អ្នករើសអើង ឬមាក់ងាយដល់អ្នក? | | | | | |
| 12) តើអ្នកដឹងទេថា មិត្តភក្តិរបស់អ្នកស្គាល់អ្នកផ្តល់សេវាសុខ-ភាពដែលអាចទៅរកដើម្បីឱ្យជួយ ប្រសិនបើមានការរើសអើង? | | | | | |
| 13) តើអ្នកមានចំណេះដឹងអំពីការបង្ហាញស្ថានភាពមេរោគអេដស៍ឬទេ? | | | | | |
| 14) តើអ្នកមានយោបល់ ឬសំណូមពរអ្វីសម្រាប់យើងទេ ដើម្បីឱ្យយើងអាចជួយអ្នកឆ្លងកាត់ស្ថានភាពនេះ ដែរឬទេ? | | | | | |
| 15) តើអ្នកអាចសួរសំណួរដល់គ្រូពេទ្យរបស់អ្នកឬទេ? | | | | | |
| **b.3 រូបមន្ត ARV - តើយុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ឆ្លើយបានត្រឹមត្រូវឬទេ៖** | | | | | |
| 16) តើ ARV គឺជាអ្វី ហើយតើវាមានដំណើរការដូចម្តេចដែរ? | | | | | |
| 17) តើឱសថ/ថ្នាំរបស់អ្នកមានឈ្មោះអ្វីដែរ? | | | | | |
| 18) តើអ្វីអាចនឹងកើតឡើងចំពោះសុខភាពរបស់អ្នកប្រសិនបើមិនលេបថ្នាំរបស់អ្នកជាទៀងទាត់? | | | | | |
| 19) តើហេតុអ្វីបានជាត្រូវតាមដានមើលតេស្តកោសិកា CD4 ហើយញឹកញាប់ប៉ុណ្ណាដែរ? | | | | | |
| 20) តើហេតុអ្វីបានជាត្រូវតាមដានតេស្តរាប់បន្ទុកមេរោគ ហើយញឹកញាប់ប៉ុណ្ណា? | | | | | |
| **b.4 EAC (ការប្រកាន់ខ្ជាប់តាមការព្យាបាល)- តើយុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ ឆ្លើយបានត្រឹមត្រូវឬទេ៖** | | | | | |

| | | | | | |
|---|---|---|---|---|---|
| 21) ហេតុអ្វីបានការលេបថ្នាំរាល់ថ្ងៃ គឺជាការសំខាន់? | | | | | |
| 22) តើអ្នកដឹងពីរបៀបថែរក្សាការប្រកាន់ខ្ជាប់ការព្យាបាល? ឬអ្នកធ្វើយ៉ាងណាដើម្បីឱ្យប្រាកដថា អ្នកលេបថ្នាំរាល់ថ្ងៃ? | | | | | |
| 23) តើអ្វីអាចកើតឡើងចំពោះសុខភាពរបស់អ្នក ប្រសិនបើអ្នកមិនលេបថ្នាំរាល់ថ្ងៃ? | | | | | |
| 24) មានហេតុផលអ្វីខ្លះដែលអ្នកផ្តល់សេវាសុខភាពប្តូររូបមន្តព្យាបាល? | | | | | |
| **b.5 សុខភាពផ្លូវភេទ និងសុខភាពបន្តពូជ, ជំងឺកាមរោគ, ការធ្វើផែនការគ្រួសារ ឬការពន្យារកំណើត)- តើយុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ ឆ្លើយបានត្រឹមត្រូវឬទេ៖** | | | | | |
| 25) តើអ្នកយល់ពីគោលគំនិតជាមូលដ្ឋានរបស់សុខភាពផ្លូវ-ភេទ និងសុខភាពបន្តពូជឬទេ? (ពោលគឺ តើបញ្ហាសុខភាពអ្វីខ្លះដែលសំខាន់ដែលត្រូវគិតនៅពេលរួមភេទ (ឧទា. ការការពារ, ផែនការគ្រួសារ, ជំងឺកាមរោគ... ។ល។)?) | | | | | |
| 26) តើអ្នកអាចរៀបរាប់ពីរបៀបថែរក្សាសុខភាពផ្លូវភេទនិងសុខភាពបន្តពូជ ឱ្យបានល្អសម្រាប់មនុស្សក្នុងវ័យដូចអ្នកបានឬទេ? | | | | | |
| 27) តើអ្នកដឹងថាអ្វីខ្លះជាការអនុវត្តល្អសម្រាប់សុខភាពជុំវិញការរួមភេទ? | | | | | |
| 28) តើអ្នកដឹងពីកន្លែង និងវិធីដែលអ្នកអាចស្វែងរកព័ត៌មានបន្ថែមអំពីឥរិយាបថផ្លូវភេទប្រកបដោយសុខភាពល្អដែរឬទេ? | | | | | |
| 29) តើអ្នកដឹងហេតុអ្វីបានជាមនុស្សឆ្លងជំងឺកាមរោគដែរឬទេ? | | | | | |
| 30) តើអ្នកដឹងវិធីបង្ការជំងឺកាមរោគដែរឬទេ? | | | | | |
| 31) តើអ្នកដឹងពីទីកន្លែងដែលត្រូវទទួលបានចំណេះដឹងអំពីជំងឺកាមរោគនិងសេវាដែរឬទេ? | | | | | |

| | | | | | |
|---|---|---|---|---|---|
| 32) តើអ្នកដឹងហេតុអ្វីបានជាមនុស្សត្រូវការផែនការគ្រួសារ? | | | | | |
| 33) តើអ្នកដឹងពីទីកន្លែងដែលត្រូវទទួលបានចំណេះដឹងអំពីផែនការគ្រួសារនិងសេវាពន្យារកំណើត ដែរឬទេ? | | | | | |
| **b.6 ការបង្ការវិជ្ជមាន- តើយុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ ឆ្លើយបានត្រឹមត្រូវឬទេ៖** | | | | | |
| 34) តើអ្នកអាចប្រាប់បានទេតើការបង្ការវិជ្ជមានគឺជាអ្វី? | | | | | |
| 35) តើអ្នកស្គាល់ ឬដឹងថានរណាខ្លះប្រឈមមុខនឹងការឆ្លង? | | | | | |
| 36) តើអ្នកដឹងពីរបៀបការពារមនុស្សពីការឆ្លងជំងឺដែលពាក់ព័ន្ធនឹងការរួមភេទឬទេ? | | | | | |
| **ពិន្ទុសរុប b.1 + b.2 + b.3 + b.4 + b.5 + b.6** **(សម្រាប់ការវាយតម្លៃក្រោយអន្តរកាល៖ បើពិន្ទុ 1-15 = អន់; 16-24 = មធ្យម; >24 = អាចទទួលយកបាន។ ពិន្ទុចាប់ពី >20, អាចប្តូរទៅកម្រិតអប់រំទី III)** | | | | | |
| | | | | | |
| **ថ្ងៃខែឆ្នាំ វាយតម្លៃ** | ថ្ងៃខែឆ្នាំ (មុន) ……………… | | ថ្ងៃខែឆ្នាំ (ក្រោយ) ……………… | | |
| **បរិយាយ/សេចក្តីថ្លែងការណ៍** *(ពិន្ទុ៖ ចម្លើយ "Yes"=1, "No" = 0)* | Yes | No | Yes | No | **កំណត់សម្គាល់** |
| **ការអប់រំកម្រិតទី III** | | | | | |
| **c.1 ការផ្តល់ថ្នាំរយៈពេលវែង MMD- តើយុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ ឆ្លើយបានត្រឹមត្រូវឬទេ៖** | | | | | |
| 1) តើអ្នកមកទទួលថ្នាំ ARV ញឹកញាប់ប៉ុណ្ណា? (ឧទា. 2, 3 ខែម្តង) | | | | | |
| 2) តើអ្នកដឹងថាតើ ការផ្តល់ថ្នាំរយៈពេលវែង MMD គឺជាអ្វីឬទេ? ហើយវាមានគោលបំណងអ្វី? | | | | | |

| | | | | | |
|---|---|---|---|---|---|
| <u>**សម្គាល់៖**</u> ប្រសិនបើដឹង (yes) បន្តទៅសំណួរទី ៣ ។ បើទេ (no), រំលងទៅសំណួរទី ៣ ហើយអ្នកផ្តល់សេវាគួរណែនាំ MMD ដល់អ្នកជំងឺ។ | | | | | |
| 3) តើអ្នកប្រាប់បានទេថា តើលក្ខណវិនិច្ឆ័យនៃភាពសមស្រប នៃ MMD មានអ្វីខ្លះ? | | | | | |
| **c.2 ជំងឺទូទៅដែលឆ្លងក្នុងពេលតែមួយ - តើយុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ ឆ្លើយបានត្រឹមត្រូវឬទេ៖** | | | | | |
| 4) **ទូទៅ៖** តើអ្នកធ្លាប់បានឮអំពីការឆ្លងជំងឺក្នុងពេលតែមួយ ជាមួយមេរោគអេដស៍ដែរឬទេ? | | | | | |
| 5) បើធ្លាប់ (yes), តើជំងឺឆ្លងដែលកើតក្នុងពេលតែមួយ ចម្បងអ្វីខ្លះដែលអាចធ្វើឱ្យលក្ខខណ្ឌសុខភាពរបស់អ្នករស់នៅជាមួយមេរោគអេដស៍កាន់តែធ្ងន់ធ្ងរ? | | | | | |
| 6) **របេង (TB):** តើអ្នកធ្លាប់ឮអំពីជំងឺរបេងដែរឬទេ? | | | | | |
| 7) បើធ្លាប់ (yes), តើអ្នកដឹងហេតុអ្វីបានជាអ្នកត្រូវការ ការព្យាបាលបង្ការជំងឺរបេង? | | | | | |
| 8) បើដឹង (yes), តើអ្នកដឹងពីទីកន្លែង និងពេលវេលាដែលត្រូវទទួលការព្យាបាលឬទេ? | | | | | |
| 9) **ជំងឺរលាកថ្លើម ប្រភេទC :** តើអ្នកធ្លាប់បានឮអំពីការឆ្លង HCV? | | | | | |
| 10) បើធ្លាប់ (yes), តើអ្នកដឹងហេតុអ្វីបានជាអ្នករស់នៅជាមួយមេរោគអេដស៍ ប្រឈមមុខនឹងការឆ្លងជំងឺ HCV ក្នុងពេលតែមួយ? | | | | | |
| 11) បើដឹង (yes), តើអ្នកដឹងហានិភ័យកាន់តែច្រើនអ្វីខ្លះដែលពាក់ព័ន្ធជាមួយមេរោគអេដស៍? | | | | | |
| 12) បើដឹង (yes), តើអ្នកដឹងពីទីកន្លែង និងពេលវេលាដែលត្រូវទទួលការព្យាបាលដែរឬទេ? | | | | | |

| | | | | | |
|---|---|---|---|---|---|
| **c.3 ចំនួនមេរោគ មិនអាចរាប់បាន = មិនអាចចម្លងបាន (U=U)**<br>**- តើយុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ ឆ្លើយបានត្រឹមត្រូវឬទេ៖** | | | | | |
| 13) តើអ្នកដឹងពីវិធីបង្ការការចម្លងមេរោគអេដស៍ដល់ដៃគូ ឬទារកក្នុងផ្ទៃ ដែរឬទេ? | | | | | |
| 14) តើអ្នកដឹងរបៀបថែរក្សាសុខភាពរបស់អ្នក ដូចអ្នក មិនឆ្លងមេរោគអេដស៍ដទៃទៀត ដែរឬទេ? | | | | | |
| **ពិន្ទុសរុប c.1 + c.2 + c.3**<br>**(សម្រាប់ការវាយតម្លៃក្រោយអន្តរកាល៖ បើពិន្ទុ 1-6 = អន់; 7-9 = មធ្យម; >9 = អាចទទួលយកបាន)** | | | | | |

## អន្តរកាលសម្រាប់ ការផ្ទេរចេញ សម្រាប់យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ អាយុ ១៥ ឆ្នាំ ឡើងទៅ

**ឧបសម្ព័ន្ធទី ៣៖** ការវាយតម្លៃការត្រៀមខ្លួនរបស់អ្នកជំងឺមុនពេលយុទ្ធសាស្ត្រផ្ទេរចេញ/ថែរក្សាទុក, ផែនការអន្តរកាលបុគ្គល និងទម្រង់ព័ត៌មាន

| **ផ្នែកទី I: ការវាយតម្លៃការត្រៀមខ្លួនរបស់អ្នកជំងឺ** | | | |
|---|---|---|---|
| **B1. ការយល់ដឹងពីស្ថានភាពមេរោគអេដស៍**<br>**(ពិន្ទុ៖ ចម្លើយ "Yes"=1, "No" = 0)** | **ចម្លើយរបស់អ្នកជំងឺ** | | **សម្គាល់** |
| | Yes | No | |
| 1) តើអ្នកត្រូវបានគេបង្ហាញអំពីស្ថានភាពមេរោគអេដស៍របស់អ្នកឬទេ? | | | |
| 2) ការស្វែងយល់ចំណេះដឹងជាមូលដ្ឋានអំពីមេរោគអេដស៍ | | | |
| 3) ការស្វែងយល់គោលបំណងនៃតេស្ត CD4 | | | |
| 4) ការស្វែងយល់គោលបំណងនៃការធ្វើតេស្តរាប់បន្ទុកមេរោគ (VL) | | | |

| | | | |
|---|---|---|---|
| 5) ការស្វែងយល់អំពីការវិវឌ្ឍនៃមេរោគអេដស៍ អន្តរកម្មជាមួយកោសិកា CD4 T? | | | |
| B2. ចំណេះដឹងអំពីសុខភាពរបស់គាត់៖ | Yes | No | |
| 6) តើអ្នកយល់អ្វីខ្លះ ដែលធ្វើឱ្យមានការផ្លាស់ប្តូរដល់លក្ខខណ្ឌសុខភាពរបស់អ្នក? | | | |
| 7) តើអ្នកគ្រប់គ្រងតម្រូវការព្យាបាលប្រចាំថ្ងៃរបស់អ្នក និងយល់ពីសារៈសំខាន់នៃឱសថដែលអ្នកប្រើដែរឬទេ? | | | |
| 8) តើអ្នកមានបញ្ហាអ្វីជាមួយការព្យាបាលប្រចាំថ្ងៃរបស់អ្នកដែរឬទេ? | | | |
| 9) តើអ្នកដឹង/យល់លទ្ធផលនៃតេស្តឈាមចុងក្រោយបំផុតរបស់អ្នកឬទេ? | | | |
| B3. ការយល់ដឹងវិធីថែរក្សាសុខភាពឱ្យបានល្អ | Yes | No | |
| 10) តើអ្នកប្រើប្រាស់គ្រឿងស្រវឹង ថ្នាំជក់ និងបារី និង/ឬឥរិយាបថកាត់បន្ថយហានិភ័យ ដែរឬទេ? | | | |
| 11) តើអ្នកបន្តប្រើ ART ទោះបីជាអ្នកមិនស្រួលខ្លួន ដែរឬទេ? | | | |
| 12) តើពេលអ្នកឈឺដូចជាផ្តាសាយ អ្នកដឹងថាត្រូវធ្វើអ្វីខ្លះទេ? | | | |
| 2.4 ដឹងពីបំណិនជីវិតរបស់ពួកគេ | Yes | No | |
| 13) តើអ្នកមានទូរស័ព្ទសម្រាប់ប្រើក្នុងករណីបន្ទាន់ដែរឬទេ? | | | |
| 14) តើអ្នកមានលេខទូរស័ព្ទរបស់មិត្តភក្តិនិងក្រុមគ្រួសារដើម្បីហៅ ក្នុងករណីបន្ទាន់ដែរឬទេ? | | | |
| 15) តើអ្នកទទួលខុសត្រូវក្នុងការធ្វើការណាត់ជួបជាមួយអ្នកផ្តល់សេវារបស់អ្នកដែរឬទេ? | | | |
| 16) តើអ្នកទទួលខុសត្រូវក្នុងការទៅបើកថ្នាំ/ដាក់បំពេញថ្នាំរបស់អ្នកឡើងវិញដែរឬទេ? | | | |
| 17) តើអ្នកមានអ្នកថែទាំ អ្នកជំនួយសុខភាពនៅផ្ទះដែរឬទេ? | | | |

| 2.5 ដឹងពីរបៀបប្រាស្រ័យទាក់ទងដោយប្រសិទ្ធភាព | Yes | No | |
|---|---|---|---|
| 18 ) តើអ្នកអាចសួរសំណួរដល់អ្នកផ្តល់សេវាសុខភាពរបស់អ្នកឬទេ ? | | | |
| 19 ) តើអ្នកអាចទាក់ទងក្រុមគាំទ្រយុវវ័យ/មនុស្សពេញវ័យ ដែរឬទេ ? | | | |
| កម្រិតទី III | | | |
| 2.6 បង្ហាញពីសកម្មភាពផ្លូវភេទប្រកបដោយការទទួលខុសត្រូវ៖ | Yes | No | |
| 20 ) តើអ្នកយល់ពីតេស្តពិនិត្យផ្ទៃពោះដែរឬទេ ? | | | |
| 21 ) តើអ្នកយល់ពីទំនាក់ទំនងរវាងមេរោគអេដស៍ និងការមានផ្ទៃពោះដែរឬទេ ? | | | |
| 22 ) តើអ្នកយល់ពីហានិភ័យនៃការរំលូតកូន និងផលប៉ះពាល់នៃការមានផ្ទៃពោះឆាប់ពេកដែរឬទេ ? | | | |
| 23 ) តើអ្នកអាចជៀសវាងការបៀតបៀនផ្លូវភេទ និងវិធីស្វែងរកការគាំទ្រនៅពេលត្រូវការដែរឬទេ ? | | | |
| 24 ) តើអ្នកដឹងថា តើជំងឺកាមរោគគឺជាអ្វីទេ ហើយតើវាអាចប៉ះ-ពាល់អ្នកដូចម្តេច ហើយតើត្រូវបង្ការជំងឺកាមរោគដោយវិធីណាឬទេ ? | | | |
| 2.7 ព័ត៌មានទាក់ទងនឹងសុខភាពបន្តពូជ | Yes | No | |
| 25 ) តើអ្នកដឹងអំពីការពន្យារកំណើតឬទេ និងដឹងតើត្រូវទៅរកការប្រឹក្សាអំពីសេវាពន្យារកំណើតនៅពេលណាដែរឬទេ ? | | | |
| 26 ) តើអ្នកយល់ពីបញ្ហានានាដែលទាក់ទងនឹងការមានផ្ទៃពោះវ័យក្មេង/មិនបានគ្រោងទុកដែរឬទេ ? | | | |

**បញ្ជីផ្ទៀងផ្ទាត់ #01: អន្តរកាលរបស់យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ (សម្រាប់យុវវ័យ)**

គោលបំណងនៃបញ្ជីផ្ទៀងផ្ទាត់អន្តរកាលយុវវ័យនេះ គឺដើម្បីត្រួតពិនិត្យចំណេះដឹងរបស់យុវវ័យ និងការទទួលយករបស់ពួកគេចំពោះការផ្ទេរចេញពីទីតាំង ART សម្រាប់កុមារ ទៅកាន់ទីតាំង ART សម្រាប់មនុស្សពេញវ័យ ។ អន្តរ-កាលរបស់អ្នកអាចតម្រូវឱ្យផ្លាស់ប្តូរអ្នកផ្តល់សេវាថែទាំសុខភាពនិងការថែទាំសុខភាពរបស់អ្នកផងដែរ ដូច្នេះ អ្នកគួរតែពិភាក្សាជាមួយអ្នកផ្តល់សេវាថែទាំសុខភាពនិងអាណាព្យាបាលរបស់អ្នក ដើម្បីធានាថា អ្នករៀបចំខ្លួនបានយ៉ាងល្អនៅមុនពេលអន្តរកាលរបស់អ្នក ។ ដើម្បីធានាការផ្ទេរចេញដោយរលូន អ្នកត្រូវធ្វើកិច្ចការមួយចំនួនដូចខាងក្រោមនេះ ។ បញ្ជីផ្ទៀងផ្ទាត់ព័ត៌មាននេះ នឹងជួយយុវវ័យឱ្យគិតអំពីការថែទាំដោយខ្លួនឯង ។

**ផ្អែកលើពិន្ទុ អ្នកផ្តល់សេវាសុខភាពនឹងគូសចំណុចទាំងឡាយខាងក្រោមនេះដើម្បីកំណត់ពីការយល់ដឹងរបស់យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ មុនពេលអន្តរកាល ៖**

- ☐ យល់អំពីមេរោគអេដស៍/ជំងឺអេដស៍ និងការថែទាំសុខភាពរបស់ពួកគេ;
- ☐ យល់អំពីសុខភាពផ្លូវភេទនិងសុខភាពបន្តពូជ;
- ☐ ដឹងរូបមន្ត ARV របស់ពួកគេ និងលេបថ្នាំតាមការណែនាំ ហើយប្រសិនបើពួកគេភ្លេចលេបថ្នាំ ARV ពួកគេនឹងដឹងពីវិធីដោះស្រាយ;
- ☐ ដឹងពីរបៀបរៀបចំ ARV របស់ពួកគេ ដោយផ្អែកលើវេជ្ជបញ្ជារបស់គ្រូពេទ្យ;
- ☐ ចូលរួមក្នុងការណាត់ជួបទាំងអស់ជាមួយអ្នកផ្តល់សេវាសុខភាពរបស់ពួកគេ និង ការថែទាំសុខភាពនៅសហគមន៍;
- ☐ អាចដោះស្រាយបញ្ហានានានៅពេលពួកគេជួបប្រទះបញ្ហាប្រឈម;
- ☐ អាចស្វែងរកការគាំទ្រពីមូលដ្ឋានសុខាភិបាលផ្សេងទៀត និងពីសហគមន៍;
- ☐ អាចរៀបចំផែនការអន្តរកាលរបស់ពួកគេ មុនពេលផ្ទេរចេញ ។

**បញ្ជីផ្ទៀងផ្ទាត់ #02: អន្តរកាលរបស់យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ (សម្រាប់អាណា-ព្យាបាល)**

គោលបំណងនៃបញ្ជីផ្ទៀងផ្ទាត់ព័ត៌មាននេះ គឺដើម្បីផ្តល់ព័ត៌មានអំពីការចុះឈ្មោះយុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ នៅក្នុងដំណើរការត្រៀមអន្តរកាល ដល់អាណាព្យាបាលរបស់ពួកគេ ។ លើសពីនេះទៀត បញ្ជីផ្ទៀងផ្ទាត់នេះក៏មានបំណងផ្តល់ព័ត៌មាន ដល់អាណាព្យាបាលពីរបៀបគាំទ្រយុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ នៅក្នុង

ដំណើរការនៃត្រៀមអន្តរកាលនេះ ពីទីតាំង ART សម្រាប់កុមារ រហូតដល់អន្តរកាល ដោយជោគជ័យ ទៅកាន់ទីតាំង ART សម្រាប់មនុស្សពេញវ័យ ។ អន្តរកាលរបស់យុវវ័យគឺជាដំណើរការនៃការផ្លាស់ប្តូរទៅជាការថែទាំខ្លួនឯង ដែលមានការលំបាកខ្លាំងសម្រាប់អ្នកជំងឺជាយុវវ័យ ។ បញ្ហានេះគឺដោយសារតែយុវវ័យត្រូវដោះស្រាយបញ្ហាប្រឈមជាច្រើនដែលពួកគេអាចនឹងកំពុងជួបប្រទះ ។ ក្រៅពីនេះ ពួកគេត្រូវរៀនពីរបៀបគ្រប់គ្រងមេរោគអេដស៍ ។ រយៈពេលនេះក៏អាចជារយៈពេលដ៏សំខាន់មួយសម្រាប់គ្រួសាររបស់យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ ដោយសារអ្នកជំងឺដែលជាយុវវ័យរស់នៅជាមួយមេរោគអេដស៍ទាំងនេះ អាចប្រើប្រាស់សិទ្ធិក្នុងការគ្រប់គ្រងខ្លួនឯងនិងការសម្រេចចិត្ត ។ នៅក្នុងដំណាក់កាលត្រៀមអន្តរកាលនេះ អ្នកផ្តល់សេវាថែទាំសុខភាព អាណាព្យាបាល និងសហគមន៍ លើកទឹកចិត្តឱ្យយុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ ទទួលខុសត្រូវខ្ពស់ដោយខ្លួនឯងចំពោះសុខភាពរបស់ពួកគេ ។

*សូមប្រើបញ្ជីផ្ទៀងផ្ទាត់ព័ត៌មានខាងក្រោមនេះ ដើម្បីបញ្ជាក់ថា អ្នកជំងឺនៅក្រោមការមើលតាមដាន សម្រាប់ត្រៀមអន្តរកាល ហើយក្នុងនាមជាអាណាព្យាបាល ពួកគេនឹងគាំទ្រយុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ ដើម្បីទទួលខុសត្រូវខ្ពស់ក្នុងការថែទាំសុខភាពរបស់ពួកគេ ។*

**សមត្ថភាពរបស់យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ ក្នុងការធ្វើកិច្ចការទាំងឡាយខាងក្រោម ដោយមានការគាំទ្រពីអាណាព្យាបាលរបស់ពួកគេ ៖**

- ☐ គោរពតាមដំបូន្មានរបស់អ្នកផ្តល់សេវាសុខភាព, ទទួលថ្នាំ ARV ដោយខ្លួនឯង និងប្រើប្រាស់ ARV ឱ្យបានត្រឹមត្រូវដោយខ្លួនឯង
- ☐ ធ្វើការណាត់ជួបជាមួយអ្នកផ្តល់សេវាថែទាំសុខភាពដោយខ្លួនឯង និងមកតាមការណាត់ជួបរបស់ពួកគេឱ្យទាន់ពេលវេលា ។
- ☐ រៀបចំមធ្យោបាយដឹកជញ្ជូនផ្ទាល់ខ្លួនសម្រាប់ការណាត់ជួបរបស់ពួកគេ ។
- ☐ កត់ត្រាពេលវេលាណាត់ជួប ដើម្បីជួបជាមួយអ្នកផ្តល់សេវាថែទាំសុខភាព និងការណាត់ជួបផ្សេងទៀត
- ☐ អាចទទួលបានសេវាសង្គមផ្សេងទៀតនៅក្នុងសហគមន៍របស់ពួកគេ និងមូលដ្ឋានសុខាភិបាល/សេវាថែទាំសុខភាពផ្សេងទៀត
- ☐ អាចប្រាប់/ពិភាក្សាបញ្ហាសុខភាពរបស់ពួកគេជាមួយអ្នកផ្តល់ការថែទាំសុខភាព និងអ្នកផ្តល់ប្រឹក្សា ។

**(តាមជម្រើស) ថ្ងៃខែឆ្នាំ៖** ............/.............../..................

ហត្ថលេខា / ស្នាមមេដៃ

ឈ្មោះរបស់អាណាព្យាបាល៖ ......................................

**បញ្ជីផ្ទៀងផ្ទាត់ #03: អន្តរកាលរបស់យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ (សម្រាប់អ្នកផ្តល់សេវា)**

គោលបំណងនៃបញ្ជីផ្ទៀងផ្ទាត់ព័ត៌មាននេះ គឺដើម្បីរំលឹក និងប្រើឧបករណ៍សំខាន់ៗផ្សេងទៀត ដែលអាចជួយសម្រាប់អ្នកផ្តល់សេវាថែទាំសុខភាព ដើម្បីវាយតម្លៃពីការត្រៀមខ្លួនរួចរាល់របស់យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ សម្រាប់អន្តរកាលរបស់ពួកគេ ។

**ខាងក្រោមនេះ គឺជាកិច្ចការចាំបាច់សម្រាប់អ្នកផ្តល់ប្រឹក្សា គួស មុនពេលផ្ទេរយុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ ទៅកាន់សេវា ART សម្រាប់មនុស្សពេញវ័យ ៖**

- ☐ យុវវ័យនិងអាណាព្យាបាលរបស់ពួកគេ រៀបចំខ្លួនបានយ៉ាងល្អសម្រាប់អន្តរកាល ។
- ☐ អ្នកផ្តល់សេវាថែទាំកុមារ បានទាក់ទងទៅកាន់អ្នកផ្តល់សេវាថែទាំមនុស្សពេញវ័យ ដើម្បីជូនដំណឹងអំពីអន្តរកាលយុវ័យ មុនពេលផ្ទេរពួកគេចេញ ។
- ☐ អ្នកផ្តល់សេវាសុខភាពបានបំពេញទម្រង់សង្ខេបអ្នកជំងឺរួចហើយ (អន្តរកាលសម្រាប់ការផ្ទេរចេញ សម្រាប់យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ អាយុ ១៥ ឆ្នាំ ឧបសម្ព័ន្ធទី ៣) ចំនួន ១ ច្បាប់ និង លិខិតបញ្ជូន (អាស្រ័យលើរដ្ឋបាលមន្ទីរពេទ្យ)
- ☐ យុវវ័យបានបំពេញកិច្ចការទាំងអស់ដូចនៅក្នុងបញ្ជីត្រួតពិនិត្យយុវវ័យ ។
- ☐ យុវវ័យបានឆ្លើយត្រឹមត្រូវយ៉ាងតិច ៥០% សម្រាប់សំណួរទាំងអស់ ទាក់ទងនឹងចំណេះដឹង អំពីមេរោគអេដស៍/ជំងឺអេដស៍ ។
- ☐ យុវវ័យថែរក្សាបាននូវការប្រកាន់ខ្ជាប់តាមការព្យាបាលកាន់តែប្រសើរ និងមានផែនការនៅពេលអនាគត
- ☐ យុវវ័យអាចប្រាស្រ័យទាក់ទងជាមួយអ្នកផ្តល់សេវាថែទាំសុខភាពក្នុងពេលផ្លាស់ប្តូរសុខភាពនិងផ្តល់ព័ត៌មាននៅពេលពួកគេត្រូវការការគាំទ្របន្ទាន់។
- ☐ ត្រូវការការគាំទ្រផ្នែកចិត្តសាស្រ្តដែលត្រូវដោះស្រាយដោយក្រុមបុគ្គលិកសង្គមកិច្ចរបស់មន្ទីរពេទ្យ។
- ☐ យុវវ័យបានទៅមើលទីតាំង ART សម្រាប់មនុស្សពេញវ័យ មុនពេលអន្តរកាល ។
- ☐ យុវវ័យ/អាណាព្យាបាលបានយល់អំពីដំណើរការនេះ ហើយព្រមទទួលយកការផ្ទេរទៅកាន់ទីតាំង ART សម្រាប់មនុស្សពេញវ័យ ។

**(ជាជម្រើស) ថ្ងៃខែឆ្នាំ:** ........... /............../..............

ហត្ថលេខា / ស្នាមមេដៃ

ឈ្មោះរបស់អ្នកផ្តល់ប្រឹក្សា៖ ..............................................

## ឧបករណ៍ក្រោយអន្តរកាល

### **ឧបសម្ព័ន្ធទី ៤៖** ការវាយតម្លៃសម្រាប់ ក្រោយពេលផ្ទេរចេញ (អ្នកផ្តល់សេវា/ អង្គការ/អ្នកផ្តល់ប្រឹក្សា)

*កំណត់សម្គាល់៖*

- *ការតាមដានបន្តគួរត្រូវបានធ្វើនៅចន្លោះ ៣ ទៅ ១២ ខែម្តង; និង បន្ទាប់ពី យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ រក្សាការណាត់ជួបបើកថ្នាំ ARV ចំនួន ២ ដង ដែលមានលទ្ធផលល្អ ។*
- *ប្រសិនបើការតាមដានបន្ត នៅពេលណាត់ជួបលើកទី ២ ដែលមានលទ្ធផលល្អ ពីរដងហើយ គេអាចបញ្ឈប់ការតាមដានបន្ត ហើយយុវវ័យដែលរស់នៅជាមួយមេរោគអេដស៍គួរតែបន្តការតាមដាន ARV ដូចគ្នា នឹងការណាត់ជួបរបស់មនុស្សពេញវ័យផ្សេងទៀតដែរ ។*
- *ប្រសិនបើការណាត់ជួបលើកទី ១ ឬលើកទី ២ របស់យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ មិនបានបង្ហាញលទ្ធផលល្អ/លទ្ធផលមិនដូចគ្នានៅសេវា ART ថ្មីសម្រាប់មនុស្សពេញវ័យ អ្នកផ្តល់ប្រឹក្សាគួរតែបន្តដោះស្រាយបញ្ហាកង្វល់របស់យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍ ។ គួរធ្វើការតាមដានបន្ថែមយ៉ាងតិច ២ ដងទៀត ។*

| **ព័ត៌មានអំពីអ្នកជំងឺ** | |
|---|---|
| លេខសម្គាល់គ្លីនិកអ្នកជំងឺ៖ ..............................<br>ភេទ៖....................................................<br>.........................................................<br>ឈ្មោះអ្នកផ្តល់ប្រឹក្សា៖ .................................. | លេខសម្គាល់អ្នកជំងឺ (លេខART): ...................<br>ឈ្មោះទីតាំង ART មនុស្សពេញវ័យថ្មី៖<br>.........................................................<br>អាយុ៖...............................................<br>ថ្ងៃខែឆ្នាំ៖............................................ |

1. តើអ្នកចងចាំថ្ងៃខែឆ្នាំណាត់ជួបចុងក្រោយរបស់អ្នកទេ? ☐ Yes សូមបញ្ជាក់: ......... ☐ No
2. តើអ្នកធ្លាប់ខកខានការណាត់ជួបរបស់អ្នកទេ? ☐ Yes ☐ No
3. តើមានមូលហេតុអ្វីខ្លះចំពោះការខកខាននោះ?

☐ ភ្លេច ☐ គ្មានមធ្យោបាយធ្វើដំណើរ

☐ មិនបានដឹងពីការណាត់ជួបនោះ ☐ មិនមានអារម្មណ៍ល្អចង់មក

☐ ឈឺពេកមិនអាចមកបាន ☐ ខ្មាសអៀន

☐ ពាក់ព័ន្ធនឹងការងារ ☐ ធុញទ្រាន់

☐ ផ្សេងទៀត.........................

4. តើអ្នកមានការណាត់ជួបបន្ទាប់ឬទេ ? ☐ បើមាន, នៅពេលណា ? ……. ☐ No

5. តើអ្នកយល់ដូចម្តេចដែរអំពីសេវាសម្រាប់មនុស្សពេញវ័យ ?

………………………………………………………………………………………………………………

………………………………………………………………………………………………………………

6. តើអ្នកស្គាល់ឈ្មោះគ្រូពេទ្យរបស់អ្នកឬទេ ? ☐ ស្គាល់ សូមបញ្ជាក់៖ ........... ☐ No

7. តើអ្នកស្គាល់ឈ្មោះអ្នកផ្តល់ប្រឹក្សារបស់អ្នកឬទេ ? ☐ ស្គាល់ សូមបញ្ជាក់៖ ........... ☐ No

8. តើអ្នកមានលេខទំនាក់ទំនងរបស់អ្នកផ្តល់ការថែទាំរបស់អ្នក ឬគ្លីនិករបស់អ្នកឬទេ ?

   ☐ មាន សូមបញ្ជាក់៖ ………………………………. ☐ No

9. តើអ្នកធ្វើដូចម្តេច ប្រសិនបើអ្នកចង់ជួបគ្រូពេទ្យរបស់អ្នក នៅមុនថ្ងៃណាត់ជួប ?

………………………………………………………………………………………………………………

………………………………………………………………………………………………………………

10. នៅពេលអ្នកឈឺមុនថ្ងៃណាត់ជួប តើអ្នកធ្វើអ្វីខ្លះ ?

………………………………………………………………………………………………………………

………………………………………………………………………………………………………………

11. តើអ្នកមានមិត្តភក្តិនៅឯទីតាំងសេវាសម្រាប់មនុស្សពេញវ័យឬទេ ?

   ☐Yes សូមបញ្ជាក់៖ ……………………………………☐ No

12. ក្នុងពេលថ្មីៗនេះ តើអ្នកបានធ្វើតេស្តកោសិកា CD4 ឬតេស្តរាប់បន្ទុកមេរោគ ឬទាំងពីរ ដែរឬទេ ?

   ☐ Yes សូមបញ្ជាក់៖ …………………………………☐ No

13. តើអ្នកដឹងលទ្ធផលតេស្តកោសិកា CD4 ឬតេស្តរាប់បន្ទុកមេរោគរបស់អ្នក ឬទាំងពីរ ដែរឬទេ ?

   ☐ Yes សូមបញ្ជាក់៖ …………………………………☐ No

14. តើអ្នកស្គាល់ឈ្មោះថ្នាំ ARV របស់អ្នកដែរឬទេ ? ☐ Yes សូមបញ្ជាក់៖ ……………☐ No

15. តើអ្នកដឹងពីកំរិតដូសដែលត្រូវប្រើ ដែរឬទេ ? ☐ Yes សូមបញ្ជាក់៖ ……………☐ No

16. ក្នុងរយៈពេល ៣ ថ្ងៃកន្លងមក តើអ្នកបានរំលងការលេបថ្នាំរបស់អ្នកប៉ុន្មានថ្ងៃ ?

   ☐ គ្មាន

   ☐ មួយថ្ងៃ

☐ ពីរថ្ងៃ

☐ បីថ្ងៃ

17. តើអ្នកធ្លាប់មានផលវិបាក ចាប់តាំងពីពេលអ្នកបានផ្ទេរមកកាន់សេវាមនុស្សពេញវ័យដែរឬទេ ?

☐ Yes សូមបញ្ជាក់៖ ................................... ☐ No

18. តើអ្នកមានដៃគូឬទេ ?

☐ មាន ( ចូលទៅសំណួរទី 19 ) ☐ No ( រំលងទៅសំណួរទី 22 )

19. តើអ្នកធ្លាប់រួមភេទជាមួយគាត់ឬទេ ?

☐ Yes ( ចូលទៅសំណួរទី 20 ) ☐ No ( រំលងទៅសំណួរទី 21 )

20. តើអ្នកប្រើស្រោមអនាម័យរាល់ពេលដែលអ្នករួមភេទដែរឬទេ ? ☐ Yes ☐ No

21. តើអ្នកយល់អំពីសារៈសំខាន់នៃស្រោមអនាម័យដែរឬទេ ? ☐ Yes ☐ No

22. តើអ្នកមានបំណងរៀបការជាមួយនរណាម្នាក់ដែរឬទេ ? ☐ Yes ☐ No

23. តើអ្នកមានគំនិតអ្វីអំពីការពន្យារកំណើតដែរឬទេ ? ☐ Yes ☐ No

24. តើអ្នកមានការងារធ្វើឬទេ ? ☐ Yes សូមបញ្ជាក់៖.............. ☐ No

## ឧបសម្ព័ន្ធទី ៥៖ ការវាយតម្លៃដោយប្រើប្រាស់ រង្វាស់ទុក្ខព្រួយរបស់ Kessler ( K10 )

### រង្វាស់ Kessler វាស់វែង ទុក្ខព្រួយ ( K10 )

Kessler Psychological Distress Scale (K10)

| ប៉ុន្មានដង ដែលអ្នកធ្លាប់មាន រោគសញ្ញា ដូចខាងក្រោម៖ នៅក្នុងរយៈពេល ៤ សប្តាហ៍ ចុងក្រោយ អ្នកមានអារម្មណ៍ថា៖ How often have you experienced the following symptoms? In the last 4 weeks, | | មិនដែល Never 1 | មានពេល តិចតួច A little of the time 2 | មានពេល ខ្លះ Some of the time 3 | មានសឹងតែរាល់ពេល Most of the time 4 | មានគ្រប់ពេល All the time 5 |
|---|---|---|---|---|---|---|
| K1 | អស់កំលាំងខ្លាំង ដោយគ្មានមូលហេតុ<br>Did you feel tired out for no good reason? | | | | | |
| K2 | ភ័យខ្លាច<br>Did you feel nervous? | | | | | |
| K3 | ភ័យខ្លាច ដែលគ្មានអ្វី អាចជួយអោយធូរបាន<br>Did you feel so nervous that nothing could calm you down? | | | | | |
| K4 | អស់សង្ឃឹម<br>Did you feel hopeless? | | | | | |
| K5 | ខ្វល់ខ្វាយ អន្ទះសារ<br>Did you feel restless of fidgety? | | | | | |
| K6 | រសាប់រសល់ នៅមិនស្ងៀម<br>Did you feel so restless you could not sit still? | | | | | |
| K7 | ពិបាកចិត្ត<br>Did you feel depressed? | | | | | |
| K8 | ត្រូវការខិតខំប្រឹងប្រែងយ៉ាងខ្លាំង ក្នុងការធ្វើអ្វីមួយ<br>Did you feel that everything was an effort? | | | | | |
| K9 | មានទុក្ខព្រួយខ្លាំង ដែលគ្មានអ្វី អាចអោយអ្នករីករាយបាន<br>Did you feel so sad that nothing could cheer you up? | | | | | |
| K10 | ខ្លួន គ្មានតម្លៃ<br>Did you feel worthless? | | | | | |
| បូកសរុបពិន្ទុ ពី K1 ដល់ K10<br>Sum scores from 1 to 10 | | | | | | |

ការបកស្រាយ (Score Interpretation):

| | | |
|---|---|---|
| ពិន្ទុ Score <20 | សុខភាពផ្លូវចិត្តល្អ (Likely to be well) | កំណត់សំគាល់: មិនមែនសំរាប់ប្រើ ចំពោះអ្នកជំងឺសរសៃប្រសាទនោះទេ |
| ពិន្ទុ Score 20-24 | កំរិតមានទុក្ខព្រួយ តិចតួច (Mild level of distress) | |
| ពិន្ទុ Score 25-29 | កំរិតមានទុក្ខព្រួយ មធ្យម (Moderate level of distress) | |
| ពិន្ទុ Score >30 | កំរិតមានទុក្ខព្រួយ ធ្ងន់ធ្ងរ (Severe level of distress) | |

# សេចក្តីបន្ថែម

## សេចក្តីបន្ថែម ទី១: រូបមន្តជម្រើសព្យាបាលសម្រាប់យុវវ័យ

| ART ជួរទីមួយ | ជួរទីមួយ ដែលបានណែនាំ | ជួរទីមួយ ជាជម្រើសជំនួស | កាលទេសៈពិសេស * |
|---|---|---|---|
| មនុស្សពេញវ័យ + យុវវ័យ + ទម្ងន់ 20 kg – 30 kg | ABC + 3TC + DTG* | ABC + 3TC + EFV 400 | AZT + 3TC + DTG<br>AZT + 3TC + EFV 400<br>AZT + 3TC + LPV/r<br>ABC + 3TC + LPV/r |
| មនុស្សពេញវ័យ + យុវវ័យ + ទម្ងន់ > 30 kg | TDF + 3TC + DTG* | TDF + 3TC + EFV 400** | ABC + 3TC + DTG<br>ABC + 3TC + EFV 400<br>AZT + 3TC + DTG<br>AZT + 3TC + EFV 400<br>TDF + 3TC + ATV/r (or LPV/r)***<br>TAF****+ 3TC + DTG |

* ការពន្យារកំណើតប្រកបដោយប្រសិទ្ធភាពគួរត្រូវបានផ្តល់ជូនស្ត្រីពេញវ័យ និងក្មេងស្រីជំទង់ក្នុងវ័យបន្តពូជ ឬមានសក្តានុពលនៃការមានកូន ។ DTG អាចត្រូវបានចេញវេជ្ជបញ្ជាជូនស្ត្រីពេញវ័យនិងក្មេងស្រីជំទង់ក្នុងវ័យបន្តពូជឬមានសក្តានុពលមានផ្ទៃពោះដែលមានបំណងចង់បានកូន ឬដែលមិនប្រើឬទទួលបានមធ្យោបាយការពារកំណើតជាប់លាប់ និងប្រកបដោយប្រសិទ្ធភាព ប្រសិនបើពួកគេបានទទួលព័ត៌មានពេញលេញអំពីហានិភ័យកាន់តែខ្ពស់ចំពោះទារកដែលមានលលាដ៏ក្បាលបិទមិនជិត (នៅពេលមានផ្ទៃពោះដំបូង និងរហូតដល់ចុងត្រីមាសទីមួយ) ។ ប្រសិនបើស្ត្រីដឹងថាមានផ្ទៃពោះបន្ទាប់ពីត្រីមាសទីមួយ, DTG គួរតែត្រូវបានចាប់ផ្តើមប្រើ ឬបន្តសម្រាប់រយៈពេលនៃការមានផ្ទៃពោះ ។ Dolutegravir (DTG) គឺជាផ្នែកមួយនៃក្រុម ARVs ថ្មី៖ the integrase strand transfer inhibitors (INSTIs) ។ DTG ផ្តល់គុណសម្បត្តិផ្នែកគ្លីនិក និងកម្មវិធី ច្រើនជាង efavirenz (EFV) សម្រាប់ប្រើក្នុងការព្យាបាលជួរទីមួយ ។

* * EFV 400 mg ត្រូវបានរំពឹងថា មានសុវត្ថិភាពសម្រាប់ស្ត្រីមានផ្ទៃពោះ ដូច EFV 600 mg ។ EFV 400 mg អាចប្រើរួមគ្នាជាមួយ rifampicin ដែលព្យាបាលរបេង, ដោយមានភាពធន់ល្អពេលប្រើរួមគ្នា និងកំហាប់ប្លាស្មាត្រូវបានថែរក្សាលើសកម្រិតដែលត្រូវបានចាត់ទុកថាមានប្រសិទ្ធភាព ។

* * * ATV/r ត្រូវបានផ្តល់នៅពេលទម្ងន់ ≥ 35 kg.

* * * *TAF អាចត្រូវបានពិភាក្សាសម្រាប់អ្នកដែលមានពោគពុកឆ្អឹង និង/ឬ ខូចមុខងារតម្រងនោម ប្រសិនបើមាន ។

# សេចក្តីបន្ថែម ទី២: កម្រិតប្រើ ARV

| រូបមន្ត | កម្រិតប្រើសម្រាប់កុមារ គិតតាមទម្ងន់ (គក) | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ផលិតផល ARV | 3 - 3.9 | 4-5.9 | 6 - 9.9 | 10 - 13.9 | 14 - 19.9 | 20 - 24.9 | 25 - 29.9 | 30 - 34.9 | 35 - 39.9 |
| AZT/3TC/NVP 300/150/200 mg | | | | | | | 2 | 2 | 2 |
| AZT/3TC/NVP 60/30/50 mg | 2 | 2 | 3 | 4 | 5 | 6 | | | |
| AZT/3TC 300/150 mg | | | | | | | 2 | 2 | 2 |
| AZT/3TC 60/30 mg | 2 | 2 | 3 | 4 | 5 | 6 | | | |
| TDF/3TC/EFV 300/300/400 mg | | | | | | | | 1 | 1 |
| TDF/3TC 300/300 mg | | | | | | | | 1 | 1 |
| ABC/3TC 600/300 mg | | | | | | | 1 | 1 | 1 |
| ABC/3TC 120/60 mg | 1 | 1 | 1.5 | 2 | 2.5 | 3 | | | |
| NVP 200 mg | | | | 1 | 1.5 | 1.5 | 2 | 2 | 2 |
| NVP 100ml susp - bottles | 10 | 10 | 16 | | | | | | |
| EFV 600 mg | | | | | | | | | |
| EFV 200 mg | | | | 1 | 1.5 | 1.5 | 2 | 2 | 2 |
| ABC 300 mg | | | | | 1 | 2 | 2 | 2 | 2 |
| ABC 60mg | 2 | 2 | 3 | 4 | | | | | |
| TDF 300 mg | | | | | | | | 1 | 1 |
| ATV/r 300/100mg | | | | | | | 1 | 1 | 1 |
| LPV/r 200/50 mg | | | | | | | 4 | 4 | 4 |
| LPV/r 100/25 mg | | | | 3 | 4 | 4 | 6 | | |
| LPV/r 40/10mg Granules | 4 | 4 | 6 | 8 | 10 | 12 | | | |
| LPV/r 80+20 ml - in ml | 2 | 3 | 3 | 4 | 5 | 6 | | | |
| DTG 50mg | | | | | | 1 | 1 | 1 | 1 |
| TDF+3TC+DTG ( 300/300/50 ) - 30 tab | | | | | | | | 1 | 1 |

## សេចក្ដីបន្ថែមទី ៣ ៖ សូចនាករត្រួតពិនិត្យតាមដានអន្តរកាលរបស់យុវវ័យដែលរស់នៅជាមួយមេរោគអេដស៍

| | | | | | |
|---|---|---|---|---|---|
| ឆ្នាំ | | ត្រីមាស | | | |
| សរុបខេត្ត/ក្រុង | | ២៥ ខេត្ត/ក្រុង | | | |
| ប្រភេពនៃទីតាំង ART | | ទីតាំង PAC | | ទីតាំង ART មនុស្សពេញវ័យ | |
| ប្រភេទ | | អាយុ | ភេទ | | សរុប |
| | | | ប្រុស | ស្រី | |
| A. ចំនួនយុវវ័យ ALHIV ដែលបានរាយការណ៍ត្រៀមអន្តរកាល | ចំនួនអ្នកជំងឺ ALHIV ដែលសមស្របសម្រាប់ត្រៀមអន្តរកាល | 10 - 12 | | | |
| | | 13 - 14 | | | |
| | | 15 - 19 | | | |
| | ចំនួនអ្នកជំងឺ ALHIV ដែលបានចុះឈ្មោះក្នុងដំណើរការអន្តរកាល | 10 - 12 | | | |
| | | 13 - 14 | | | |
| | | 15 - 19 | | | |
| | ចំនួនអ្នកជំងឺ ALHIV ដែលត្រូវបានជួយបង្ហាញស្ថានភាពមេរោគអេដស៍ តាមរយៈវគ្គផ្ដល់ប្រឹក្សា | 10 - 12 | | | |
| | | 13 - 14 | | | |
| | | 15 - 19 | | | |
| B. ចំនួន ALHIV ដែលបានរាយការណ៍ក្នុងអំឡុងពេលអន្តរកាល | | | | | |
| B. 1 – ផ្ទេរចេញ | ចំនួនអ្នកជំងឺ ALHIV ដែលត្រៀមរួចរាល់ដើម្បីផ្ទេរចេញទៅសេវាមនុស្សពេញវ័យ | 10 - 12 | | | |
| | | 13 - 14 | | | |
| | | 15 - 19 | | | |
| | ចំនួនអ្នកជំងឺ ALHIV ដែលត្រូវបានជួយបង្ហាញស្ថានភាពមេរោគអេដស៍ តាមរយៈវគ្គផ្ដល់ប្រឹក្សា | 10 - 12 | | | |
| | | 13 - 14 | | | |
| | | 15 - 19 | | | |
| | ចំនួនអ្នកជំងឺ ALHIV ដែលបានទទួលការអប់រំ ( កម្រិតទី I, II, & III ) | 10 - 12 | | | |
| | | 13 - 14 | | | |
| | | 15 - 19 | | | |
| | | 10 - 12 | | | |
| | | 13 - 14 | | | |

| | | | | | |
|---|---|---|---|---|---|
| | ចំនួន ALHIV ដែលបោះបង់សេវា (ក្នុងពេលផ្ទេរចេញ/ថែរក្សា) (សូមបែងចែកការបោះបង់សេវា ឬស្លាប់) | 15 - 19 | | | |
| **B. 2 - ការថែរក្សា** | ចំនួនអ្នកជំងឺ ALHIV ដែលត្រូវបានរក្សាទុកក្នុងទីតាំង ART ដដែល (នឹងប្តូរទៅ B.2 - ការថែរក្សា) | 10 - 12 | | | |
| | | 13 - 14 | | | |
| | | 15 - 19 | | | |
| | ចំនួនអ្នកជំងឺ ALHIV ដែលត្រូវបានជួយបង្ហាញស្ថានភាពមេរោគអេដស៍ តាមរយៈវគ្គផ្តល់ប្រឹក្សា | 10 - 12 | | | |
| | | 13 - 14 | | | |
| | | 15 - 19 | | | |
| | ចំនួនអ្នកជំងឺ ALHIV ដែលបានទទួលការអប់រំ (កម្រិត I, II, & III) | 10 - 12 | | | |
| | | 13 - 14 | | | |
| | | 15 - 19 | | | |
| | ចំនួន ALHIV ដែលបោះបង់សេវា (ក្នុងពេលផ្ទេរចេញ/ថែរក្សា) (សូមបែងចែកការបោះបង់សេវា ឬស្លាប់) | 10 - 12 | | | |
| | | 13 - 14 | | | |
| | | 15 - 19 | | | |
| **C. ចំនួន ALHIV ដែលបានរក្សាក្នុងអំឡុងពេលក្រោយអន្តរកាល** | ចំនួន ALHIV ដែលបានផ្ទេរដោយជោគជ័យពី PAC និងចុះឈ្មោះនៅទីតាំង ART មនុស្សពេញវ័យ (ក្រោយ 3-6 ខែ) | 15 - 19 | | | |
| | ចំនួន ALHIV ដែលបានរក្សាទុកក្នុង PAC | 15 - 19 | | | |
| | ចំនួន ALHIV ដែលបានបោះបង់សេវា (រួមទាំងចំនួន ALHIV ដែលបានស្លាប់) | 15 - 19 | | | |
| | ចំនួនអ្នកជំងឺ ALHIV <u>**សរុប**</u> ដែលបានទទួលការអប់រំដោយជោគជ័យ (សរុប = កម្រិតទី I+ II+ III) | 15 - 19 | | | |
| | a. ការអប់រំកម្រិតទី I | | | | |
| | b. ការអប់រំកម្រិតទី II | | | | |
| | c. ការអប់រំកម្រិតទី III | | | | |

# ឯកសារយោង


1) UNAIDS. HIV and AIDS data hub for Asia Pacific: Data Section: Factsheets: Country Factsheets: Cambodia. 2018. Accessed on 1st Sep 2019 at http://aphub.unaids.org/.

2) Bekker LG, Hosek S. HIV and adolescents: focus on young key populations. Journal of the International AIDS Society. 2015;18 (2Suppl 1).

3) World Health Organization (WHO). HIV and adolescents: guidance for HIV testing and counselling and care for adolescents living with HIV: recommendations for a public health approach and considerations for policy-makers and managers. Geneva, Switzerland: WHO; 2013.

4) Lowenthal ED, Bakeera-Kitaka S, Marukutira T, Chapman J, Goldrath K, Ferrand RA. Perinatally acquired HIV infection in adolescents from sub-Saharan Africa: a review of emerging challenges. Lancet Infect Dis. 2014;14(7):627-639.

5) Health for the World's Adolescents: A Second Chance in the Second Decade. Geneva, Switzerland:World Health Organization; 2014.

6) Haynes RB, Sackett DL, Richardson WS, Rosenberg W, Langley GR. Evidence-based medicine: How to practice & teach EBM. Canadian Medical Association. Journal. 1997 Sep 15;157(6):788.

7) AMC. Age limits and adolescents. Paediatric Child Health, 2003; 8(9): 577, https://www.ncbi.nlm.nih.gov/pmc/articles/PMC2794325/.

8) World Health Organization (WHO). HIV and adolescents: guidance for HIV testing and counseling and care for adolescents living with HIV: recommendations for a public health approach and considerations for policy-makers and managers. Geneva, Switzerland: WHO; 2013.

9) Blum RW, Garell D, Hodgman CH, Jorissen TW, Okinow NA, Orr DP, Slap GB. Transition from child-centered to adult health-care systems for adolescents with chronic conditions: a position paper of the Society for Adolescent Medicine. Journal of Adolescent Health. 1993 Nov 1;14(7):570-6.

10) WHO, 2011: Guideline on HIV disclosure counselling for children up to 12 years of age (see Appendix B for Summary of Findings and GRADE Tables comparing children disclosed to with those who are not disclosed to, online at http:// www.who.int/hiv/topics/vct/en/index.html)

ឧបត្ថម្ភបោះពុម្ពដោយ

UNAIDS GHSC-PSM